ភាគ១ ព្រះពុទ្ធសង្ឃក្នុងឋានៈជាអ្នកកសាងសន្តិភាព

# ការសំរុះសំរួល ប្រកបដោយសតិ

## សៀវភៅណែនាំ ដោះស្រាយជំលោះ តាមព្រះពុទ្ធសាសនា

២១៤.
៤៨

ដោយ

ហ្គូមនិ. ម៉ុកឆុនណៃរាប

www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

www.budinst.gov.kh     www.elibraryofcambodia.org

LIBRARY
BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

២១៤.៤៨

ភាគ១ ព្រះពុទ្ធអង្គក្នុងឋានៈជាអ្នកកសាងសន្តិភាព

# ការសំរុះសំរួលប្រកបដោយសតិ

## សៀវភៅណែនាំ

## ដោះស្រាយជំលោះ

## តាមព្រះពុទ្ធសាសនា

LIBRARY
BUDDHIST INSTITUTE
២៩៧/៩៩

ដោយ
ហ្ចូអន. ម៉ុកខុនណែល
JOHN A. MCCONNELL

CCCR CDRI

www.budinst.gov.kh www.elibraryofcambodia.org

**មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់**

**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

ផ្ទះលេខ ៥៦ ផ្លូវលេខ ៣១៥ ទួលគោក ភ្នំពេញ

(ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ១ កម្ពុជា)

ទូរស័ព្ទ: ៨៥៥២៣ ៣៦ ៧១១៥

ទូរសារ: ៨៥៥២៣ ៣៦ ៦០៩៤/៤២៦១០៣

E-mail: cdri.pp.cam@uni.fi

© វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ១៩៩៨

**រក្សាសិទ្ធិគ្រប់យ៉ាង** - គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទំរង់បែបបទ និងតាមអត្ថន័យផ្សេងៗ៖ អេឡិចត្រូនិច យន្តកម្ម ថតចំលង ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខអក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។

**«ការសំរុះសំរួលប្រកបដោយសតិ - សៀវភៅណែនាំដោះស្រាយជំលោះតាមព្រះពុទ្ធសាសនា»** បានបោះពុម្ពជាលើកទីមួយក្នុងឆ្នាំ១៩៩៥ ជាភាសាអង់គ្លេស នៅទីក្រុងបាងកកដោយវិទ្យាស្ថានស្រាវជ្រាវព្រះពុទ្ធសាសនា សកលវិទ្យាល័យព្រះពុទ្ធសាសនាមហាចុឡា ចលនាផ្លូវព្រលឹងក្នុងការអប់រំ (Spirit in Education Movement-SEM) អាស្រមវង្សានិត (Wongsanit Ashram) និងមូលនិធិដើម្បីកុមារ ។

អ្នកនិពន្ធ John McConnell រក្សាសិទ្ធិគ្រប់យ៉ាង ចំពោះអត្ថបទជាភាសាអង់គ្លេស ។

រៀបចំ និងរចនាដោយ DESIGN GROUP ភ្នំពេញ កម្ពុជា

បោះពុម្ពដោយ Singapore Press ភ្នំពេញ កម្ពុជា

www.budinst.gov.kh www.elibraryofcambodia.org

# មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់



មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ១៩៩៦ ជាមជ្ឈមណ្ឌលឯករាជ្យ ស្ថិតនៅក្រោមការជួយឧបត្ថម្ភគាំទ្រ ពីវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។

មជ្ឈមណ្ឌលជួយគាំទ្រព្រោមជ្រែង ដល់សហគមន៍នៃអ្នកអនុវត្តផ្ទាល់ ក្នុងការដោះស្រាយជំលោះ នូវវគ្គបណ្តុះបណ្តាលជំនាញ និងធនធាន ដើម្បីបង្កើន និងពង្រីកសមត្ថភាពប្រជាជន និងស្ថាប័នកម្ពុជា ក្នុងការដោះស្រាយជំលោះ ។

មជ្ឈមណ្ឌលកើតឡើងដោយមានការសហការពីសំណាក់ អង្គការរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល ដែលចាប់អារម្មណ៍ ក្នុងដំណើរការអភិវឌ្ឍន៍ ការការពារ គ្រប់គ្រង និងដោះស្រាយទំនាស់ ។

បេសកកម្មរបស់មជ្ឈមណ្ឌលគឺ ការកសាងសមត្ថភាពរដ្ឋាភិបាល និងសង្គមស៊ីវិល ឲ្យជាប់ទាក់ទងក្នុងដំណើរការសហការ លើការងារធ្វើការសំរេចចិត្ត ។ ចំនុចផ្តោតសំខាន់នៃការប្រឹងប្រែងរបស់មជ្ឈមណ្ឌលគឺ ផ្តល់ពត៌មានដល់ដំណើរការធ្វើសំរេចចិត្តសាធារណៈ តាមរយៈការស្រាវជ្រាវ វគ្គសិក្សា និងសកម្មភាពផ្សព្វផ្សាយជាមុនផ្សេងៗទៀតរបស់មជ្ឈមណ្ឌល ។ មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់មានសង្ឃឹមថា នឹងបានចូលរួមចំណែកក្នុងការប្រឹងប្រែងដទៃទៀត ឆ្ពោះទៅរកការសំរេចឲ្យបាននូវសន្តិភាពយូរអង្វែងក្នុងប្រទេសកម្ពុជា ។



www.budinst.gov.kh www.elibraryofcambodia.org

# សេចក្ដីថ្លែងអំណរគុណ

នៅពេលដែលបុគ្គលិក និងសមាជិកនៃគណៈកម្មាធិការដឹកនាំ មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់បានត្រូវណែនាំឲ្យស្គាល់ John McConnell អ្នកនិពន្ធសៀវភៅ **«ការសំរុះសំរួលប្រកបដោយសតិ»** ជាលើកទីមួយពួកគេបានយល់ព្រមភ្លាមៗថា ការបកប្រែសៀវភៅនេះពីភាសាអង់គ្លេសទៅជាភាសាខ្មែរ និងក្លាយជាការរួមចំណែកដ៏ចាំបាច់ដល់ធនធានអក្សរសាស្ត្រ ដែលអាចជាការផ្ដល់ការគាំទ្រដល់ការងាររបស់ជនកម្ពុជា ដែលជាអ្នកអនុវត្តផ្ទាល់ក្នុងការងារដោះស្រាយជំលោះ ។ ការបោះពុម្ពផ្សាយនេះ ក៏បានក្លាយទៅជាសកម្មភាពមួយនៃគំនិតផ្ដួចផ្ដើមដំបូងជាច្រើនទៀតរបស់មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ ។ ចេញពីគំនិតផ្ដើមក្នុងការបកប្រែសៀវភៅនេះ រហូតដល់ទីបញ្ចប់នៃការបោះពុម្ព ត្រូវទាមទារនូវការប្រឹងប្រែង និងការឧបត្ថម្ភគាំទ្រពីមនុស្សជាច្រើនទៀត ។

ខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅដល់ John ដែលជាអ្នកនិពន្ធ **«ការសំរុះសំរួលប្រកបដោយសតិ»** ដោយបានផ្ដល់ការអនុញ្ញាតឲ្យមានការបកប្រែសៀវភៅនេះ ព្រមទាំងកិច្ចការទាំងអស់ដែលលោកបានជួយក្នុងការសំរួលអត្ថបទជាភាសាអង់គ្លេសជាមុនសំរាប់រៀបចំបកប្រែជាភាសាខ្មែរ ។ លោក **គង់ ចាន់** ដែលបានចំណាយពេលវេលា និងការប្រឹងប្រែងដ៏ច្រើនលើសលប់ក្នុងការបកប្រែ ។ ឯកឧត្តម **ឡឹក សេរីសុគន្ធា** និង ឯកឧត្តម **ម៉ុល លឹម** សហប្រធានមជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ ដែលបានផ្ដល់នូវទស្សនៈដ៏មានតំលៃ និងការជួយឧបត្ថម្ភទាំងស្រុងលើគំរោងនេះ ។ ឯកឧត្តម **ឈាន អឿម** អនុរដ្ឋលេខាធិការនៃក្រសួងធម្មការ និងសាសនា និង **វ៉ែន ឈួន** បុគ្គលិកវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដែលបានចំណាយពេលវេលាដ៏មានតំលៃក្នុងការសំរួលកែប្រែ និងផ្ទៀងផ្ទាត់ការបកប្រែ ។ វិចិត្រករ **ហោ គឹមឡូហ៊ាន** និង**អេង ចន្ធា** ដោយបានបង្ហាញនូវគត៌ិភាពតាមរយៈការរចនារូបភាពដ៏ល្អប្រណិត ។ លោកRichard McDonough និងបុគ្គលិក Design Groupទាំងអស់ដែលបានជួយផ្ដល់គំនិត និងទទួលរៀបចំទំព័រ ។

ឆ្លៀតឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់អ្នកដែលបានផ្ដល់ជំនួយជាអាទិភាពរួមមាន៖ SIDA និង NOVIB ដែលបានផ្ដល់ជំនួយហិរញ្ញវត្ថុ អាចបង្កលទ្ធភាពឲ្យយើងបំពេញការងារនេះបានល្អប្រសើរ និងជាពិសេសដំនៀទុកចិត្តរបស់គេលើទស្សនៈវិស័យរយៈពេលវែងរបស់វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងមជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ ។ គណៈកម្មាធិការបម្រើក្វេគ័រអាមេរិកាំង (AFSC) ដែលបានជួយផ្ដល់នូវការឧបត្ថម្ភផ្នែកស្មារតី និងថវិកា



www.budinst.gov.kh www.elibraryofcambodia.org

ដល់ការបោះពុម្ពសៀវភៅនេះ ។

ជាទីបញ្ចប់នេះ ខ្ញុំក៏សូមទទួលស្គាល់ផងដែរនូវការងារជាច្រើន ដែលជាវិភាគទានរបស់បុគ្គលិកនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ ដែលមានជាអាទិ៍ៈ **ឌី សុន**, **សុខ ផ្កាយច័ន្ទ** និង **ឃេង ម៉ាឡៃន** ។ សៀវភៅដែលអស់លោកអ្នកកំពុងកាន់អាននេះ ពុំអាចកើតចេញជារូបរាងបានទេ បើសិនជាគ្មានការខិតខំប្រឹងប្រែង និងទឹកចិត្តស្វាមីភក្តិ ដែលផុសចេញពីទស្សនៈរបស់ពួកគេក្នុងការបង្កើតឲ្យមានសន្តិភាពពិតៗច្រើនថែមទៀតក្នុងប្រទេសកម្ពុជា ។

**អេវ៉ា មីស្លីវិក**

*សហប្រធានមជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់*
*នាយិកាវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*



www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណរបស់អ្នកនិពន្ធ

ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកទាំងឡាយខាងក្រោម ។សៀវភៅនេះមិនអាចកើតចេញជាផ្លែផ្កា និងរូបរាងបានទេបើគ្មានការសហការ និងជួយឧបត្ថម្ភពីសំណាក់អស់លោកអ្នកទាំងអស់នោះទេ ។

ការអញ្ជើញជាបន្តបន្ទាប់របស់មិត្តដ៏ល្អរបស់ខ្ញុំម្នាក់ឈ្មោះ **ប្រាជា ហុតានុវ៉ាត្រ** ដែលជំរុញខ្ញុំឲ្យធ្វើការជាមួយក្រុមព្រះពុទ្ធសាសនានៅប្រទេសថៃ ។ អង្គការនានាដែលខ្ញុំបានធ្វើការជាមួយ បានរីកចំរើនចេញពីទស្សនៈរបស់ **សុលក់ សិវារក្ស** ។ ការកំណត់របស់គាត់គឺ ការដាក់ស្នើព្រះធម៌ទៅលើបញ្ហាសង្គម ជួយបង្កើតនូវរូបរាងនៃបរិបទខាងក្នុង ដែលការងាររបស់ខ្ញុំផ្ដល់លើការដាក់ស្នើនេះចំពោះទំនាស់ត្រូវបានសារទេរ ។ ទោះបីជាខ្ញុំមិនដែលបានជួបព្រះគ្រូសង្ឃរាជ **ឃោស** ក៏ដោយចុះ ប៉ុន្តែខ្ញុំឲ្យតំលៃស្នាដៃនៃការសរសេររបស់គាត់ ។ ភាពច្បាស់លាស់ និងការចង្អុលបង្ហាញ ដែលគាត់បានលើកឡើងគឺជាការដាក់បញ្ចូលភាពពិតនៃផ្លូវព្រលឹង និងជំនឿទុកចិត្ត ដែលគាត់បានផ្ចិតផ្ចង់ដោយជោគជ័យលើទំលាប់ដ៏មានប្រជាប្រិយដែលទាញចេញពីកត្តានេះ ឲ្យទៅជានិរន្តភាពនៃការបំផុសចំណង់ ។

ព្រះ **ប៉ៃសាល វិសាលោ** និងព្រះតេជគុណ **គឹម តេង** បានស្នើផ្សេងៗគ្នា ឲ្យខ្ញុំសរសេរសៀវភៅណែនាំសំរុះសំរួលសំរាប់អ្នកកាន់សាសនាព្រះពុទ្ធ ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះអ្នកដែលបានជួយផ្ដល់យោបល់ ដល់ពង្រាងដែលធ្វើឡើងប្រកបដោយជោគជ័យ ជាពិសេស **អាន់ឌ្រូ គួរេល** ព្រះ**ប៉ៃសាល វិសាលោ** (ជាអ្នកកែសំរួលការបោះពុម្ពជាភាសាថៃ) **អេរិកា គេមប៊ិ** និង **សានតិការ៉ូ ម៉ិកឃុ** ។ **សានតិការ៉ូ ម៉ិកឃុ** ដែលបានទទួលស្គាល់ជាពិសេសក្នុងការយល់ដឹងការប្រើប្រាស់ពាក្យព្រះពុទ្ធសាសនា និងអត្ថបទ តែគាត់មិនបានទទួលខុសត្រូវលើកំហុសផ្សេងទៀតទេ ។ យើងមិនយល់ស្របគ្នា ចំពោះចំនុចជាច្រើន ប៉ុន្តែពាក្យទូន្មាន និងការជួយឧបត្ថម្ភរបស់គាត់មិនអាចកាត់ថ្លៃបានឡើយ ។

គំនិតនៃការបង្កើតសៀវភៅនេះ បានជាប្រធានបទនៃវគ្គសិក្សាផ្សេងៗ រយៈពេល៤០សប្តាហ៍នៅប្រទេសថៃ កម្ពុជា និងស្រីលង្កា ។ ប្រហែលជាពាក់កណ្តាលនៃសិក្ខាកាម គឺលោកសង្ឃ និងដូនជីសល់ពីនោះមកពីអង្គការក្រៅរដ្ឋាភិបាល ដែលជាប់ទាក់ទងក្នុងការងារដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ ។ ខ្ញុំរៀនបានច្រើន ឬថា លើសអ្វីដែលខ្ញុំបានរៀនក្នុងវគ្គសិក្សានោះទៅទៀត ។ ពួកគេជាប្រភពនិរន្តនៃការបង្កើតការទាក់ទាញអារម្មណ៍ ។

វគ្គសិក្សាលើកទីមួយរបស់ខ្ញុំនៅកម្ពុជា បានត្រូវរៀបចំឡើងដោយ "ក្រុមចំរុះដើម្បីសន្តិភាព និងការផ្សះផ្សារ " (ធម្មយាត្រា) ។ ខ្ញុំរីករាយនឹងធ្វើការជាមួយលោកសង្ឃខ្មែរ ហើយខ្ញុំចង់លើកឡើងជាពិសេសពី **លោកតាឌី** ព្រះសង្ឃរាជ "វត្តអណ្តើក " ដែលស្ថិតនៅចន្លោះពីបាត់ដំបងទៅប៉ៃលិន ដែលប្រកបដោយព្រះបញ្ញាញាណ និងភាពរាក់ទាក់ស្រស់ស្រាយ ដែលខ្ញុំចងចាំជានិច្ចកាល ។

ការប្រតិបត្តិរបស់សម្តេច ព្រះមហាឃោសានន្ទ ក្នុងការធ្វើព្រះធម៌ឲ្យទៅជាប្រភពមួយនៃសន្តិភាពក្នុងប្រទេសកម្ពុជា បានជួយផ្ដល់អំណោចដល់អ្នកកសាងសន្តិភាព មិនមែនត្រឹមតែនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងសកលលោកទាំងមូលទៀតផង ។



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំមានសេចក្ដីសោមនស្សរីករាយ ដែលសម្ដេចបានជួយជ្រោមជ្រែង និងលើកទឹកចិត្តដល់ខ្ញុំ ។ ការប្រជុំផ្សេងៗជាមួយសម្ដេចមិនមែនជាការងារសាមញ្ញទេ ។ ជាពិសេសទៀត ខ្ញុំសូមអរគុណ **លីស្សា ថែន ស្ដេន**, **ចុន្នី**, **គីម ឡេង**, **ប៉ូច ចាន់** និងបុគ្គលិកក្រុមចំរុះដើម្បីសន្តិភាព និងការផ្សះផ្សារ ក្នុងការជួយ និងការទទួលស្នាក់នៅ ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់ American Friends Service Committee និង Mennonite Central Committee ចំពោះការគាំទ្ររបស់ពួកគេ ។

បន្ទាប់មកទៀត ខ្ញុំធ្វើការជាមួយវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងសូមថ្លែងអំណរគុណដល់បុគ្គលិកវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ក្នុងការជួយជ្រោមជ្រែងរបស់ពួកគេ ។ ជាពិសេស សូមលើកឡើងផងដែរចំពោះការប្ដេជ្ញារបស់អ្នកស្រី **អេថា មីស្ទីមិក** ក្នុងការធ្វើសន្តិភាពឲ្យទៅជាផ្នែកនៃការអភិវឌ្ឍន៍ ។ លោក **ឈេមិន ម៉ាំឡូន** និង **ចំរាច** ក្នុងការជួយរៀបចំ និងផ្ដល់យោបល់របស់ពួកគេ ។ ក្នុងមហាសន្និបាតមួយរបស់វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា សម្ដេចសង្ឃរាជគណៈមហានិកាយ **ទេព វង្ស** បានមានពុទ្ធដីកាស្នើថា ព្រះសង្ឃចូលរួមយ៉ាងសកម្មក្នុងការកសាងសន្តិភាព រំឭកឡើងវិញនូវតួនាទីពីបុរាណរបស់វត្តដែលជាមជ្ឈមណ្ឌលសំរាប់សន្តិភាព និងការផ្សះផ្សារ ។ ក្នុងទស្សនៈនេះ ខ្ញុំសូមថ្លែងអំណរគុណដល់សម្ដេចផងដែរ ។

ខ្ញុំក៏សូមសំដែងនូវការដឹងគុណដល់អ្នកចូលរួមក្នុងការបកប្រែ និងការបោះពុម្ពសៀវភៅនេះជាភាសាខ្មែរ ដែលមានជាអាទិ៍ៈ ឯកឧត្តម **ឈន សៀម** អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា លោក **គង់ ចាន់** ព្រះតេជគុណ **ស៊ុខ ចាសនា** វិចិត្រករ **ហោ គីមស្រ៊ាន** និង **អេង ចន្ទ្រា** Design Group និងបុគ្គលិកវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា លោក **ឆែម ឈុន** និងលោក **ខឹ សន** ។

ខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅដល់ភរិយារបស់ខ្ញុំ **អេរិសា** និងកូនទាំងពីរ **ជុម អាដាម** និង **អ៊ីសេគ** ចំពោះការសហការ និងការគាំទ្ររបស់ពួកគេ ។ គេបានជួយរៀបចំ ក្នុងពេលដែលខ្ញុំអវត្តមានដោយវគ្គសិក្សា និងប្រឹងប្រែងបង្កលក្ខណៈងាយស្រួលឲ្យបញ្ចប់នូវពង្រាងក្នុងពេលខ្ញុំនៅផ្ទះ ។ ប្រសិនជាពួកគេមិនបង្កលក្ខណៈ និងឱកាសចាំបាច់ដល់ដំណើរការនេះទេ ប្រហែលជាខ្ញុំមិនអាចបញ្ចប់សៀវភៅនេះបានទេ ។ ខ្ញុំក៏សូមដឹងគុណផងដែរនូវការគាំទ្រពីចំងាយ ដោយទូរស័ព្ទ និងលិខិតពីម្ដាយ និងឪពុកម្ដាយក្មេករបស់ខ្ញុំ ។

JOHN A. MCCONNELL

*John McConnell មានសញ្ញាបត្របណ្ឌិតផ្នែកសាសនា ពីមហាវិទ្យាល័យ Lancaster ប្រទេសអង់គ្លេស និងធ្លាប់ជានិស្សិតនៃព្រះពុទ្ធសាសនាជាង២០ឆ្នាំ ។ គាត់មានបទពិសោធន៍ផ្ទាល់ខ្លួនច្រើនក្នុងការដោះស្រាយជម្លោះ ក៏ដូចជា ការផ្សះផ្សារវាងបុគ្គលរងគ្រោះដោយស្ថានភាពនៃសង្គ្រាមស៊ីវិល និងបានធ្វើការក្នុងប្រទេសជាច្រើនទៅលើវិស័យនេះ ។*



www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

ខ្ញុំព្រះករុណា អាត្មាភាព ខ្ញុំបានពិនិត្យ និងវិភាគរាល់ខ្លឹមសារអត្ថបទ ហើយយល់ឃើញថា **ការសំរុះសំរួលប្រកបដោយសតិ - សៀវភៅណែនាំដោះស្រាយជំលោះតាមព្រះពុទ្ធសាសនា** នេះមានអត្ថន័យ និងមានសារៈសំខាន់ណាស់សំរាប់អ្នកគតិយុត្តិធម៌ និងព្រហ្មវិហារធម៌ក្នុងសម័យនេះ ។ ដូចពាក្យថា ព្រះពុទ្ធអង្គក្នុងឋានៈជាអ្នកកសាងសន្តិភាពជាដើម ។ល ។ ក្នុងនេះសុទ្ធតែដកស្រង់យកមកចងក្រងជាសំរង់អត្ថបទ គឺជាពាក្យដំបូន្មាន ទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធភាគច្រើនលើសលប់ឥតគណនា ។ នេះជាតួខ្លឹមសារសំរាប់ឲ្យយើងទាំងអស់គ្នាធ្វើការផ្សព្វផ្សាយ ដើម្បីយកមកអនុវត្តប្រតិបត្តិក្នុងការដោះស្រាយជំលោះទ្វេភាគីក្តី ឬពហុភាគីក្តី ដែលកំពុងប្រកួតប្រជែងគ្នា ។ ពីព្រោះភាគីទាំងសងខាងពុំមានភាគីណាមួយទទួលយកកំហុសរបស់ខ្លួនត្រង់ប្រការណាមួយឡើយ ។ លុះត្រាតែអ្នកមានគតិយុត្តិធម៌ទៅបំភ្លឺ និងពន្យល់ហេតុ និងផល ដែលកើតឡើងនោះ ទើបគេទាំងសងខាងដាក់កាយ វាចា ចិត្ត ទទួលយកហេតុផលរៀងៗខ្លួន ។ ឧទាហរណ៍ ព្រះភិក្ខុវិន័យធរ និងព្រះភិក្ខុធម្មកថិកជាដើម ។ល ។ ព្រះភិក្ខុវិន័យធរចេះខាងវិន័យ ក៏ប្រកាន់ថា អាត្មាអញធ្វើត្រឹមត្រូវតាមផ្លូវវិន័យ រីឯព្រះភិក្ខុធម្មកថិកចេះខាងធម៌ ក៏ប្រកាន់ថា អាត្មាអញធ្វើត្រឹមត្រូវតាមផ្លូវធម៌ ។ ពុំមាននរណាម្នាក់ទទួលខុសត្រូវចំពោះហេតុ និងផល ដែលកើតឡើងនោះឡើយ ។

មូលហេតុដូច្នេះឯងហើយ ដែលខ្ញុំព្រះករុណា អាត្មាភាព ខ្ញុំមានបេតិប្រមោទចង់បានឲ្យសៀវភៅនេះចេញផ្សព្វផ្សាយទៅដល់អ្នកមានគតិយុត្តិធម៌ និងព្រហ្មវិហារធម៌នោះបានស្វែងយល់ ដើម្បីដោះស្រាយជំលោះដែលអាចកើតមានឡើងដោយអចេតនា ឬដោយចេតនា និងភាពហឹង្សានោះ គេទទួលយកហេតុ និងផលរបស់គេរៀងៗខ្លួន ។

ធ្វើនៅវត្តឧណ្ណាលោម ថ្ងៃច័ន្ទ ទី០៥ ខែមករា ឆ្នាំ ១៩៩៨

**សម្តេចព្រះសង្ឃរាជ**

**ទេព វង្ស**



www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

ប្រវត្តិសាស្ត្រ និងភាពជាក់ស្តែងបច្ចុប្បន្នក្នុងប្រទេសកម្ពុជា បង្ហាញឲ្យឃើញនូវទិដ្ឋភាពដែលពោរពេញទៅដោយជំលោះគ្រប់បែបយ៉ាងលើគ្រប់វិស័យ ភាគច្រើននៃជំលោះទាំងនោះនាំទៅរកភាពហិង្សា ។ តាំងពីប្រជារាស្ត្រ បញ្ញាវន្ត អ្នកស្នេហាជាតិ...រហូតដល់អ្នកដឹកនាំ សុទ្ធតែត្រូវបាន និងកំពុងទទួលនូវទុក្ខវេទនាទោះតាមផ្លូវចិត្តក្តី ផ្លូវកាយក្តី ។ ពាក្យថា «**ជំលោះ**» គឺមានន័យថា ការជំរុញឲ្យមានការផ្លាស់ប្តូរ ។ ការផ្លាស់ប្តូរអាចទៅរកភាពវិជ្ជមាន និងភាពអវិជ្ជមាន ។ ពេលណាដែលយើងមានលទ្ធភាពការពារ គ្រប់គ្រង និងដោះស្រាយជំលោះបាន គឺពេលនោះហើយ ដែលយើងមានការអភិវឌ្ឍន៍ ។ ហើយផ្ទុយមកវិញពេលណាដែលយើងមិនចេះការពារ គ្រប់គ្រង និងដោះស្រាយជំលោះ វានឹងនាំមកនូវវិនាសកម្ម មហន្តរាយ សង្គ្រាមបង្ហូរឈាម... ។ល ។

ព្រះពុទ្ធសាសនា បានចាក់ឫសយ៉ាងជ្រៅក្នុងសង្គមខ្មែរ ហើយបានក្លាយជាឧបករណ៍ ជាមជ្ឈមណ្ឌលអប់រំផ្លូវចិត្តសំរាប់ប្រជាជនខ្មែរ ក្នុងការគ្រប់គ្រង និងដោះស្រាយទំនាស់ ។ ព្រះពុទ្ធអង្គទ្រង់បានរៀបចំចងក្រងនូវវិធីល្អិតច្រើនឥតគណនាសំរាប់ធ្វើការងារជាមួយទំនាស់ប្រកបដោយសតិបញ្ញា ។ មានចំងល់មួយកើតឡើង បើព្រះពុទ្ធសាសនាមានវិធីគ្រប់គ្រាន់ ហេតុអ្វីក៏ប្រទេសទាំងឡាយ (ក្នុងនោះមានកម្ពុជាផងដែរ) ដែលកាន់ព្រះពុទ្ធសាសនា នៅតែកើតមានអំពើឃោរឃៅ និងហិង្សា? សៀវភៅរបស់លោក **ហ្វូអន ចុំគូខុនណែល «ការសំរុះសំរួលប្រកបដោយសតិ - សៀវភៅណែនាំដោះស្រាយជំលោះតាមព្រះពុទ្ធសាសនា**» នេះនឹងអាចបំភ្លឺបានក្បោះក្បាយនូវចំងល់ខាងលើ ។ ខ្ញុំព្រះករុណាអាត្មាភាព គ្រាន់តែលើកយកឧទាហរណ៍មួយមកសង្ខេបជូនថា៖«ពេលដែលយើងចង់ចេះប្រើយានយន្តថ្មីមួយ តើយើងត្រូវមើលសៀវភៅណែនាំរបៀបប្រើ និងអនុវត្តសាកល្បងផ្ទាល់ ឬក៏យកសៀវភៅណែនាំនោះ ដាក់លើហឹង ហើយអុជធូបបួងសួង?» ។

យើងគ្រប់គ្នាចង់បានសន្តិភាពកើតមាននៅក្នុងប្រទេសយើង ។ តែសន្តិភាពមិនអាចកើតឡើងដោយឯកឯងនោះទេ គ្មានផ្លូវទៅរកសន្តិភាពទេ សន្តិភាពជាផ្លូវខ្លួនឯង ។ ដូច្នេះយើងម្នាក់ៗត្រូវធ្វើអ្វីមួយដើម្បីសន្តិភាព ។ សន្តិភាពកើតមកពីមេត្តា និងករុណា ។

ខ្ញុំព្រះករុណាអាត្មាភាពគិតថា សៀវភៅដែលអស់លោកអ្នកកំពុងអាននេះ ពិតជាមានសារៈប្រយោជន៍ និងជាវិភាគទានដ៏សំខាន់ក្នុងការកសាងសន្តិភាព និងការអភិវឌ្ឍន៍យូរអង្វែងសំរាប់ប្រទេសកម្ពុជា ។ នេះជាលទ្ធផលនៃសកម្មភាពមួយ ក្នុងចំណោមសកម្មភាពជាច្រើនទៀតរបស់មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ ក្នុងការធ្វើការងារដោះស្រាយទំនាស់ ដែលប្រកបដោយភាពអហិង្សានិងការអភិវឌ្ឍន៍ជាវិជ្ជមាន ។

សូមឲ្យទុក្ខសោក រោគភ័យទាំងពួងរលត់ផុតចាកពីប្រជាពលរដ្ឋខ្មែរ និងមនុស្សលោកទាំងមូល ។

ធ្វើនៅវត្តសំពៅមាស ថ្ងៃទី១៥ ខែមករា ព.ស. ២៥៤១/គ.ស.១៩៩៨

Samdech Preah Maha Ghosananda

**សម្តេចព្រះមហាឃោសានន្ទ**



www.budinst.gov.kh www.elibraryofcambodia.org

# លំនាំដើម

ការប្រមើលមើលវត្ថុពីរ ដែលមានលក្ខណៈខុសគ្នាទាំងស្រុងពីមួយទៅមួយ ដូចអធិករណ៍ ខុសគ្នាពីព្រះធម៌ដូច្នោះ គឺជាការពិបាកណាស់ ។ នៅក្នុងអធិករណ៍យើងមានអារម្មណ៍កោធៈ និងទោសៈ ដេរគ្នាទៅវិញទៅមក និងបញ្ចេញសកម្មភាពក្នុងគោលបំណងធ្វើឲ្យមានការឈឺចាប់ទៅវិញទៅមក ។ មួយវិញទៀតយើងគិតថា ព្រះធម៌ គឺជាសរណៈដ៏សុខសាន្ត និងស្ងប់ ហើយជាស្ថានដែលស្ថិតដាច់ពីការខកចិត្ត និងការចុកចាប់នៃវិវាទ កាលណាយើងមានការរសាប់រសល់ និងមិនសប្បាយចិត្ត ។

អធិករណ៍ និងព្រះធម៌ ហាក់មានលក្ខណៈខុសគ្នាដូចទឹក និងប្រេង ប៉ុន្តែព្រះពុទ្ធអង្គទ្រង់មានព្រះបន្ទូលយ៉ាងច្រើនអំពីអធិករណ៍ និងអំពើហិង្សានេះ ។ តាមព្រះធម៌ ហឹង្សាគឺជាផលនៃមនោអកុសលកម្ម ក្នុងរបៀបដែលយើងគិត និងរស់នៅ ។តាមធម្មតានៅពេលដែលយើងជាប់ក្នុងអធិករណ៍ យើងមើលមិនឃើញនូវដំណើរការទាំងនេះទេ ហើយដំណើរការនេះ មានឥទ្ធិពលមកលើអំពើរបស់យើង ទាំងយើងមិនបានដឹងខ្លួន ។ តាមពុទ្ធសាសនា យើងអាចដោះស្រាយអធិករណ៍ដោយសន្តិវិធីបាន ដោយកត់សំគាល់ជាដំបូងនូវមូលហេតុដែលនាំឲ្យមានអធិករណ៍ ហើយបន្ទាប់មកធ្វើការដោយប៉ិនប្រសប់ដើម្បីលប់បំបាត់មូលហេតុទាំងនេះ ។ នៅក្នុងសៀវភៅប្រភេទនេះចំនួនពាភាគទៀត យើងនឹងឃើញថា តើយើងអាចប្រើប្រាស់ពុទ្ធសាសនាដើម្បីដោះស្រាយដ៏ជាក់ស្តែងនូវអធិករណ៍យ៉ាងណា?

នៅក្នុងភាគនេះ យើងនឹងសិក្សាអំពីគំនិតផ្តួចផ្តើមផ្ទាល់របស់ព្រះពុទ្ធអង្គ ក្នុងឋានៈជាអ្នកកសាងសន្តិភាព និងរកឲ្យឃើញថា តើយើងអាចរៀនបាននូវអ្វីខ្លះ ដែលពាក់ព័ន្ធនឹងការកសាងសន្តិភាពនៅពេលបច្ចុប្បន្ននេះ ។ យើងនឹងឃើញថា ព្រះពុទ្ធអង្គទ្រង់បានចូលរួមយ៉ាងសកម្មក្នុងការរកសន្តិភាព ហើយព្រះអង្គទ្រង់បានពិសោធន៍យ៉ាងច្រើន ក្នុងការអនុវត្តន៍ព្រះធម៌ទៅក្នុងអធិករណ៍ ទ្រង់ព្រមទាំងបានរៀបចំធ្វើបញ្ញត្តិនូវគុណវុឌ្ឍិសំរាប់អ្នកសំរុះសំរួល ដែលពាក់ព័ន្ធក្នុងកាលបច្ចុប្បន្ន ក៏ដូចក្នុងពេលព្រះពុទ្ធអង្គគង់នៅ ។

គេបានកត់ត្រាថា ព្រះពុទ្ធអង្គទ្រង់បានធ្វើអន្តរាគមន៍ជាច្រើនដងនៅក្នុងអធិករណ៍ ។ អត្ថបទដូចតទៅនេះគឺជាករណីពីរដ៏ប្រសើរបំផុត ដែលបានរៀបចំកត់ត្រាទុកជាឯកសារ ។

www.budinst.gov.kh www.elibraryofcambodia.org



ភិក្ខុវិន័យធរចោទភិក្ខុធម្មកថិកថា បានបន្សល់ទឹកក្នុងបន្ទប់

www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក១ ៖ ព្រះសង្ឃប្រឈ្លោះគ្នានៅកោសម្ពី

## ១.១ ចំណាប់ផ្តើមនៃអធិករណ៍

នៅកោសម្ពីក្នុងវត្តឃោសិតមានមហាថេរពីរអង្គ ដែលក្នុងមួយអង្គៗមានសិស្សគណជាព្រះសង្ឃចំនួនប្រាំរយអង្គ ។ មហាថេរទាំងពីរអង្គនេះមួយអង្គជាភិក្ខុវិន័យធរ (គ្រូបង្រៀនវិន័យ) មួយអង្គទៀតជាភិក្ខុធម្មកថិក (គ្រូបង្រៀនធម្មៈ) ។

អធិករណ៍ផ្ទុះឡើងដោយឧប្បត្តិហេតុតិចតួចមួយ ។ ថ្ងៃមួយនៅពេលដោះទុក្ខសត្វនៅក្នុងបន្ទប់ទឹករួច ភិក្ខុជាធម្មកថិក បានបន្សល់ទឹកខ្លះនៅក្នុងផ្តិលតូចមួយក្នុងបន្ទប់ទឹកនោះ ។

ភិក្ខុជាវិន័យធរបានឃើញទឹកនៅក្នុងបន្ទប់ ហើយបានសួរបន្ទោសភិក្ខុជាធម្មកថិកដូចតទៅ៖

<<ម្នាលលោកដ៏មានអាយុ តើលោកឬដែលបន្សល់ទឹកក្នុងបន្ទប់?>>

<<ករុណា គឺខ្ញុំករុណា>>

<<ប៉ុន្តែតើលោកជ្រាបទេថា ការធ្វើយ៉ាងនេះជាការខុសឆ្គង?>>

<<ពិតណាស់ ខ្ញុំករុណាមិនដឹងទេ>>

<<ប៉ុន្តែលោកដ៏មានអាយុ នេះជាកំហុស>>

<<ដូចនេះខ្ញុំករុណានឹងបំពេញព្រះទ័យលោកដ៏មានអាយុចំពោះរឿងនេះ>>

ភិក្ខុជាវិន័យធរឆ្លើយតប <<ជាការពិតណាស់ ម្នាលលោកដ៏មានអាយុ បើលោកធ្វើដោយគ្មានចេតនា លោកគ្មានកំហុសទេ>> ។ ដូចនេះភិក្ខុជាធម្មកថិកគិតថា លោកពុំមានកំហុសទេ ពីព្រោះពុំបានប្រព្រឹត្តល្មើសវិន័យបញ្ញត្តិដោយចេតនា ។

ក្នុងការព្រមទទួលនូវកំហុស និងស្នើសុំធ្វើការកែប្រែភិក្ខុជាធម្មកថិកក៏បានបង្ហាញនូវការគោរពចំពោះអំណាចរបស់ភិក្ខុជាវិន័យធរផងដែរ ។ ក្នុងចំលើយតប ភិក្ខុជាវិន័យធរ ដែលប្រហែលជាចាប់អារម្មណ៍ចំពោះការសុំទោសដោយស្មោះនៃភិក្ខុជាធម្មកថិក ក៏អត់អោនទោស និងបញ្ជាក់ពីទិរទោសរបស់លោករួចហើយ ។ ដូចនេះឧប្បត្តិហេតុនេះហាក់ដូចជាត្រូវចប់សព្វគ្រប់នៅពេលនេះ ។ ប៉ុន្តែមានព្រឹត្តិការណ៍មួយកើតឡើង នាំឲ្យអធិករណ៍នេះផ្ទុះកាន់តែខ្លាំងឡើង ។

## ១.២ ការផ្ទុះកាន់តែខ្លាំងចាប់ផ្តើម

មានពេលមួយនោះក្នុងចំណោមសិស្សគណរបស់លោក ភិក្ខុជាវិន័យធរមានថេរដីកាយ៉ាងស្ងាត់ៗថា <<ភិក្ខុជាធម្មកថិកនេះ ថ្វីបើបានប្រព្រឹត្តនូវកំហុស ប៉ុន្តែលោកពុំបានជ្រាបពីកំហុសនោះទេ>> ។

ភិក្ខុជាវិន័យធរពោលបែបនេះប្រហែលជាប្រាថ្នាចង់តម្លើងឋានៈផ្ទាល់របស់លោក ពុំមែនមានបំណងចង់បង្ខូចកិត្តិស័ព្ទរបស់ភិក្ខុជាធម្មកថិកទេ ។

សមណសិស្សដែលបំបួសដោយភិក្ខុវិន័យធរបានឆ្លៀតឱកាសយកប្រៀបលើបក្សពួកមួយក្រុមទៀតដោយនិយាយប្រាប់ពួកគេនូវការចោទប្រកាន់នោះថា <<ឧបជ្ឈាយ៍របស់អស់លោក ថ្វីបើបានប្រព្រឹត្តនូវកំហុស ប៉ុន្តែលោកពុំបានជ្រាបនូវកំហុសនោះទេ>> ។

សិស្សធម្មកថិកបានពិតទូលដល់ភិក្ខុជាធម្មកថិកនូវអ្វីដែលគេបានឮពីសិស្សវិន័យធរ ។ ភិក្ខុជាធម្មកថិកមានកំហឹងខ្លាំង ហើយបានសន្និដ្ឋានដោយប្រញាប់ប្រញាល់ថា៖ សេចក្តីប្រកាសរបស់ភិក្ខុជាវិន័យធរ ជាសេចក្តីប្រកាសមិនប្រកបដោយសច្ចៈ ។ សិស្សនៃព្រះវិន័យធរ កាលមុនពោលថា៖ <<គឺពុំមែនជាកំហុសទេ>>។ ឥឡូវលោកពោលថា៖ <<គឺជាកំហុសទៅវិញ>> ។ លោកជាអ្នកពោលនូវមុសាវាទ ។

សិស្សនៃភិក្ខុធម្មកថិក ដែលមានអារម្មណ៍ក្របាល់

www.budinst.gov.kh www.elibraryofcambodia.org

ក្រហាយ និងកំហឹង ដោយគេប្រមាថគ្រូរបស់ខ្លួន ឥឡូវមានអាវុធសំរាប់ប្រឆាំងនឹងក្រុមមួយទៀតៈ ‹‹គ្រូរបស់លោកគឺជាអ្នកប្រព្រឹត្តនូវមុសាវាទ›› ។

ដោយមានកំហឹងចំពោះការចោទប្រកាន់នោះ ភិក្ខុជាវិន័យធរបានកោះប្រជុំអ្នកគាំទ្រលោក ហើយបានកាត់ទោសបណ្តេញភិក្ខុជាធម្មកថិកចេញ ។ ‹‹ភិក្ខុជាធម្មកថិកត្រូវទទួលទោសបណ្តេញចេញពីមុខងាររបស់លោកដោយលោកប្រព្រឹត្តល្មើសនឹងវិន័យបញ្ញត្តិ និងបដិសេធមិនទទួលស្គាល់នូវកំហុសរបស់លោក›› ។

នៅពេលនោះមហាថេរទាំងពីររកឃើញជានិច្ចនូវវិធានការការពារកិត្តិនាមរៀងៗខ្លួន ពោរពេញដោយទោសៈ និងសេចក្តីសង្ស័យទៅវិញទៅមក ហើយប្រាស្រ័យទាក់ទងគ្នាតែតាមរយៈសិស្សគណរបស់លោកតែប៉ុណ្ណោះ ។យ៉ាងណាក៏ដោយ សិស្សរបស់លោក ពុំមែនជាអ្នកនាំសារដ៏គួរទុកចិត្តបំផុតទេ ព្រោះម្នាក់ៗច្របូកច្របល់ទៅដោយគំនុំទៅវិញទៅមក ។

## ១.៣ ការរីកធំឡើងនៃអធិករណ៍

ដោយឃើញថា មុខងាររបស់លោកត្រូវបានទទួលការគំរាមកំហែង ដោយសារការប្រកាសជាផ្លូវការនោះ ភិក្ខុជាធម្មកថិកក៏បានចូលទៅក្នុងភូមិទាំងឡាយ ដែលព្រះអង្គធ្លាប់សំដែងធម៌ទេសនា ដើម្បីរកការឧបត្ថម្ភពីព្រះសង្ឃ និងឧបាសក ឧបាសិកា ផិតផ្តាយឲ្យបានច្រើន ។

‹‹អាត្មាពុំបានប្រព្រឹត្តខុសទេ ។ ការកាត់ទោសបណ្តេញចេញ គឺជាការខុសច្បាប់ សូមព្រះតេជគុណ ផស់លោកគាំទ្រខ្ញុំព្រះករុណាអាត្មាភាពក្នុងការរកយុត្តិធម៌ផង›› ។

អធិករណ៍បានរីកសុសសាយទៅដល់គ្រប់អ្នកដែលមានទំនាក់ទំនងជាមួយព្រះមហាថេរទាំងពីរ ដូចជាអ្នកភូមិ ដែលរស់នៅជុំវិញវត្ត ដូនជី ដែលមកទទួលសីល ព្រមទាំងទេវតាដែលជាអ្នកថែរក្សាការពារទៀតផង ។ មិត្តភក្តិ និងអ្នកស្និទ្ធស្នាលរបស់លោករហូតដល់ឋានព្រហ្មគ្រប់សព្វទាំងអស់ សូម្បីតែអ្នកនៅក្រៅសាសនាក៏បានចូលរួមបង្កើតជាពីរបក្សដែរ ។

## ១.៤ ការផ្តួចផ្តើមសន្តិភាព

ប៉ុន្តែយ៉ាងណាក៏ដោយ ក៏ពុំមែនគ្រប់គ្នាក្នុងសហគមន៍ សុទ្ធតែបានជាប់ជំពាក់ក្នុងអធិករណ៍នោះទេ ។ មានសមណសិស្សមួយអង្គបាននិមន្តទៅទូលព្រះសម្មាសម្ពុទ្ធ អំពីសេចក្តីសង្ខេបដ៏មានតុល្យភាពនៃទស្សនៈរបស់ភាគីនីមួយៗ ។

‹‹បពិត្រព្រះអង្គដ៏ចំរើន ពួកអ្នកកាត់ទោសបណ្តេញចេញមានជំនឿថា ការបណ្តេញគឺជាការប្រតិបត្តិទៅតាមច្បាប់ ប៉ុន្តែពួកអ្នកគាំទ្រភិក្ខុ ដែលត្រូវបណ្តេញចេញមានយោបល់យល់ថា គឺជាការផ្ទុយនឹងច្បាប់›› ។

ដំបូងព្រះសម្មាសម្ពុទ្ធទ្រង់សាកល្បងដោះស្រាយអធិករណ៍ដោយ ‹‹ផ្តាំផ្ញើពាក្យសំដី›› ប្រហែលជាតាមរយៈសមណសិស្ស ដោយទ្រង់មិនបាននិមន្តយាងទៅផ្ទាល់ព្រះអង្គៈ ‹‹សូមឲ្យភិក្ខុទាំងឡាយនោះរួបរួមគ្នាឡើង›› ។

ប៉ុន្តែអ្នកនាំពាក្យបានត្រឡប់មកវិញជាមួយនឹងពត៌មានអាក្រក់ៈ ‹‹បពិត្រព្រះអង្គដ៏ចំរើន ពួកគេបដិសេធមិនរួបរួមគ្នាទេ›› ។ លុះទ្រង់បានព្រះសណ្តាប់ដូច្នោះហើយ ព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះបន្ទូលថាៈ ‹‹គណៈភិក្ខុសង្ឃកំពុងបែកខ្ញែកគ្នាហើយ›› ។

ព្រះពុទ្ធអង្គបានផ្តាំផ្ញើពាក្យទៅឲ្យភិក្ខុសង្ឃ



www.budinst.gov.kh www.elibraryofcambodia.org

ទាំងឡាយចំនួនប៉ុន្មានក្តី ប៉ុន្តែរាល់តែរងព្រះភិក្ខុសង្ឃទាំងនោះ មិនអើពើនឹងបណ្តាំនោះទេ ។ ភាពប្រាកដប្រជា ដែលព្រះពុទ្ធអង្គទ្រង់ឈ្វេងយល់អំពីការទាត់ចោលនូវពាក្យបណ្តាំនោះ មានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីសង្កេតរបស់ព្រះអង្គ ។

## ១.៥ ព្រះពុទ្ធអង្គទ្រង់សុំឱ្យមានការយោគយល់កាន់តែមានតុល្យភាពឡើង

ដោយការផ្តាំផ្ញើតាមអ្នកដទៃៗ ពុំទទួលនូវលទ្ធផលល្អ ព្រះពុទ្ធអង្គបានទ្រង់និមន្តយាងទៅជួបបក្សពួកទាំងពីរដោយព្រះអង្គផ្ទាល់ បង្ហាញប្រាប់ដល់ក្រុមដែលប្រកាសទោសបណ្តេញចេញនូវកំហុសក្នុងអំពើរបស់ខ្លួន និងដល់ក្រុមដែលបដិសេធមិនទទួលស្គាល់នូវទោសកំហុសក្នុងអំពើរបស់ខ្លួន ។ ព្រះពុទ្ធអង្គបានអំពាវនាវសុំឲ្យមានការពិនិត្យពិច័យឲ្យបានហ្មត់ចត់បំផុត ។

ជាដំបូង ព្រះពុទ្ធអង្គទ្រង់និមន្តយាងទៅរកភិក្ខុជាវិន័យធរ និងសិស្សគណរបស់លោក ហើយបានទូន្មានលោកទាំងនោះ កុំបណ្តោយឲ្យមោហ៍បាំងនូវតំលៃពិតរបស់មនុស្ស ដែលលោកទាំងនោះបានចោទប្រកាន់ ។

‹‹ដោយគ្រាន់តែមើលឃើញហាក់ដូចជាគេប្រព្រឹត្តខុស ពុំមែនមានន័យថាគេត្រូវបណ្តេញចេញទេ ។ រឿងរ៉ាវគប្បីពិចារណាដោយប្រុងប្រយ័ត្នជាទីបំផុត›› ។

អ្នកគិតថា គេបានប្រព្រឹត្តនូវកំហុសមួយ ។ គេគិតថា គេពុំមានកំហុសណាមួយទេ ។ សូមកុំបដិសេធថា ទស្សនៈរបស់គេជាទស្សនៈខុស ដោយពុំបានពិចារណាឲ្យបានត្រឹមត្រូវ ។

សូមគិតគូរដល់តំលៃរបស់គេ ។ គេជាអ្នកចេះដឹង គេជាសិស្សគណរបស់តថាគត ។ គេជាអ្នកឯកទេសខាងធម៌អាថ៌ ។ គេជាអ្នកមានគតិបណ្ឌិតមានបទពិសោធន៍ខ្ពស់ និងឈ្លាសវៃ ។ គេជាអ្នកមានហិរិឱត្តប្បៈ ប្រកបដោយការភ្ញាក់រលឹក មានឆន្ទៈចង់រៀនសូត្រ.....ពោលគឺជាសាវ័កដ៏ល្អមួយអង្គ›› ។

ព្រះពុទ្ធអង្គទ្រង់បានសុំឲ្យពួកភិក្ខុវិន័យធរពិចារណាថា តើរឿងរ៉ាវអាចនឹងក្លាយទៅជាយ៉ាងណា? បើពួកលោកនៅតែប្រកាន់ថា ត្រូវតែបណ្តេញចេញ ហើយអធិករណ៍នៅតែមិនអាចដោះស្រាយបាន ។

‹‹បើយើងបណ្តេញភិក្ខុនេះចេញ ព្រោះលោកមើលមិនឃើញអាបត្តិ យើងមិនអាចប្រតិបត្តិធម៌ជាមួយភិក្ខុនេះបានទេ....ដែលជាហេតុនាំឲ្យមានតែវិវាទជំលោះ ការមិនស្រុះស្រួលគ្នា ការវាយតប់គ្នាសំរាប់គណៈសង្ឃ ។ សង្ឃភេទ ពោលគឺការទាស់ទែងខ្វែងគំនិតគ្នាក្នុងគណៈសង្ឃនឹងកើតមានឡើង›› ។

ដូចគ្នាផងដែរ នៅពេលព្រះពុទ្ធអង្គទ្រង់និមន្តយាងទៅរកភិក្ខុធម្មកថិក ព្រះអង្គទ្រង់ទូន្មានលោកទាំងនោះឲ្យពិចារណាថា តើលោកធ្វើនេះត្រឹមត្រូវទាំងស្រុងដែរឬទេ? ហើយទ្រង់បានជំរុញលោកទាំងនោះឲ្យមានសម្បជញ្ញៈកាន់តែច្បាស់លាស់ទៅលើភិក្ខុវិន័យធរដើម្បីឲ្យលោកទាំងនោះមើលឃើញអំពើល្អនៅក្នុងពួកគេ ហើយទ្រង់ព្រមានពួកគេអំពីផលវិបាកចំពោះគណៈសង្ឃ ក្នុងការខកខានមិនបានដោះស្រាយអធិករណ៍ ។

‹‹សូមកុំសូវច្បាស់ពេកថា អស់លោកពិតជាត្រូវក្នុងករណីនេះ ។ ការទំនៀនអាចមានសច្ចៈខ្លះៗ ។ សូមមេត្តាគិតគូរដល់តំលៃភិក្ខុ ដែលជាវិន័យធរផង ។ លោកជាអ្នកប្រាជ្ញ លោកជាសិស្សគណរបស់តថាគត លោកជាអ្នកមានឯកទេសផ្នែកវិន័យ លោកមានបទពិសោធន៍ខ្ពស់ឈ្លាសវៃ លោកមានហិរិឱត្តប្បៈប្រកបដោយការភ្ញាក់រលឹកមានឆន្ទៈចង់រៀនសូត្រ ពោល



www.budinst.gov.kh www.elibraryofcambodia.org



ព្រះពុទ្ធអង្គផ្ដល់ធម៌ទេសនាដល់ព្រះភិក្ខុសង្ឃទាំងពីរក្រុម

www.budinst.gov.kh www.elibraryofcambodia.org

តិលោកជាសាវ័កដ៏ល្អមួយអង្គ›› ។

សូមពិចារណាថា៖ ‹‹បើភិក្ខុទាំងនេះបណ្តេញអាត្មាអញចេញដោយមកពីអាត្មាអញមើលមិនឃើញអាបត្តិ វិវាទ នោះការទាស់ទែងខ្វែងគំនិតគ្នាក្នុងគណៈសង្ឃនឹងកើតមានឡើង›› ។ ម្នាលភិក្ខុទាំងឡាយ អាបត្តិគប្បីត្រូវសំដែងដោយមានជំនឿ និងសេចក្តីទុកចិត្តលើអ្នកដទៃ›› ។

បន្ទាប់មក ព្រះបរមគ្រូទ្រង់ងើបពីព្រះអាសនៈ រួចទ្រង់និមន្តយាងចេញទៅ ។

ចំលើយរបស់ព្រះពុទ្ធអង្គប្រកបដោយអង្គដូចតទៅនេះ៖

* ព្រះពុទ្ធអង្គទ្រង់និមន្តយាងទៅកាន់ក្រុមនិមួយៗដោយផ្ទាល់ ។

* ព្រះពុទ្ធអង្គទ្រង់ក្រើនរំលឹកពួកភិក្ខុវិន័យធរមិកុំឲ្យឈរនៅលើអំណាចរបស់ខ្លួន ប៉ុន្តែត្រូវពិចារណានូវទស្សនៈរបស់ក្រុមម្ខាងទៀត ។

* ដោយទ្រង់ស្នើឲ្យពិចារណានូវករណីសម្មតិកម្មមួយ ព្រះពុទ្ធអង្គទ្រង់សុំឲ្យភិក្ខុទាំងឡាយនោះពិចារណាអំពីភិក្ខុ ដែលសុខចិត្តនៅក្នុងបរិបទនៃចំណេះដឹងនិងសេចក្តីសុច្ចរិតទូទៅរបស់លោក ។ យើងមិនគប្បីបណ្តោយឲ្យកំហុសរបស់មនុស្សណាមួយបាំងយើងមិនឲ្យមើលឃើញនូវគុណសម្បត្តិរបស់គេទេ ។

* ព្រះពុទ្ធអង្គទ្រង់ជំរុញភិក្ខុទាំងឡាយឲ្យពិចារណានូវផលវិបាកនៃអំពើរបស់ខ្លួនពាក់ព័ន្ធនឹងអធិករណ៍និងការខ្វែងគំនិតនៅក្នុងគណៈសង្ឃ ។ អធិករណ៍ពុំមែនគ្រាន់តែជាជំលោះផ្ទាល់ខ្លួនទេ ប៉ុន្តែជាជំលោះដែលមានការជាប់ទាក់ទងដល់គណៈសង្ឃទាំងមូល ។

## ១.៦ ព្រះពុទ្ធអង្គទ្រង់ព្រមានពីសង្ឃភេទ

ពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ពុំមានភិក្ខុអង្គណាយកព្រះទ័យទុកដាក់ទេ ព្រោះភិក្ខុទាំងពីរក្រុមនោះផ្តើមប្រតិបត្តិធម៌ដាច់ពីគ្នា ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឆ្លើយតបចំពោះទង្វើនេះដោយទ្រង់ចង្អុលបង្ហាញថា ភិក្ខុទាំងឡាយនោះបានបង្កើតឲ្យមានសហគមន៍ដោយឡែកពីគ្នាជាធរមានទៅហើយ ។ ព្រះពុទ្ធអង្គទ្រង់បានបន្តសង្កត់នូវបញ្ហានេះ ប៉ុន្តែក្រុមម្ខាងៗសុទ្ធតែមានអំណាចឬមួយបំបែកសង្ឃជាបន្តទៅទៀត ឬមួយចាត់វិធានការកសាងនូវឯកភាព ។

‹‹ភិក្ខុទាំងនេះស្ថិតក្នុងសហគមន៍ផ្សេងពីសហគមន៍របស់អ្នក ហើយអ្នកស្ថិតនៅក្នុងសហគមន៍ផ្សេងពីសហគមន៍របស់គេ ។ម្នាលភិក្ខុ! ការស្ថិតក្នុងសហគមន៍ដោយឡែកពីគ្នានេះមានហេតុបច្ច័យពីរយ៉ាង ឬមួយមកពីខ្លួនឯង ដោយខ្លួនធ្វើឲ្យខ្លួនស្ថិតនៅក្នុងសហគមន៍ដាច់ដោយឡែក ឬមួយគណៈសង្ឃទាំងមូលបណ្តេញគេចេញ ដោយគេមើលពុំឃើញ គេមិនកែប្រែ ឬគេមិនរាងចាល ។ ម្នាលភិក្ខុ ការស្ថិតក្នុងសហគមន៍ជាមួយគ្នាមានហេតុបច្ច័យពីរយ៉ាង ឬមួយខ្លួនឯងធ្វើខ្លួនឯងឲ្យស្ថិតនៅក្នុងសហគមន៍ជាមួយគ្នា ឬមួយគណៈសង្ឃទាំងមូលលើកលែងទោសចំពោះសង្ឃដែលត្រូវបានបណ្តេញចេញ›› ។

ព្រះពុទ្ធអង្គទ្រង់ណែនាំឲ្យភិក្ខុទាំងឡាយអត់ចង្ហាន់រួមគ្នាមួយថ្ងៃ ហើយចំពោះភិក្ខុទាំងឡាយនោះដែលប្រកែកគ្នានៅក្នុងសាលាឆាន់ នោកន្លែងដទៃទៀតត្រូវគង់នៅលើអាសនៈដាច់ពីគ្នានៅក្នុងសាលាឆាន់ ឬនៅកន្លែងដទៃនោះ ។

## ១.៧ ជំហានអំពីកំណើនឯកភាព

ប៉ុន្តែយ៉ាងណាក៏ដោយ ការស្តារសហគមន៍ពុំទាន់បានធ្វើនៅឡើយ ហើយព្រះភិក្ខុទាំងឡាយចាប់ផ្តើមប្រតាយប្រតប់គ្នានៅក្នុងវិហារវត្តអារាម ។ ភិក្ខុទាំង


www.budinst.gov.kh www.elibraryofcambodia.org

នោះមិនបានប្រើប្រាស់នូវអាវុធទេ ប៉ុន្តែគេវាយគ្នាដោយដៃទទេ ។ ការប្រណ្ដោះគ្នានៃភិក្ខុទាំងឡាយបានក្លាយទៅជាប្រធានបទនៃការខ្សឹបខ្សៀវជាសាធារណៈ ។

នៅពេលសង្ឃមួយអង្គក្រាបទូលថ្វាយពត៌មានអំពីការវាយគ្នា ដល់ព្រះសម្មាសម្ពុទ្ធ ព្រះពុទ្ធអង្គទ្រង់ពុំជឿទេ ។

‹‹ម្នាលភិក្ខុទាំងឡាយ តើជាការពិតដូចពោលឬដែលថា ភិក្ខុទាំងឡាយមានការវាយតប់គ្នា?››

‹‹ក្រាបទូលព្រះអង្គ ជាការពិតណាស់››

ព្រះពុទ្ធអង្គទ្រង់និមន្តយាងទៅកាន់ភិក្ខុទាំងឡាយនោះម្ដងទៀត ហើយទូន្មានភិក្ខុសង្ឃទាំងឡាយនោះអំពីវិធីបញ្ចៀសកុំឲ្យអធិករណ៍ផ្ទុះឡើងខ្លាំងរហូតដល់ក្រុតគ្រាពុំបាន ។

‹‹ម្នាលភិក្ខុទាំងឡាយ បើគណៈសង្ឃបែកបាក់គ្នា បើអមិត្តភាពកើតឡើង អ្នកទាំងឡាយត្រូវគង់លើអាសនៈរំពឹងគិតថា៖ ‹‹យ៉ាងហោចណាស់យើងមិនត្រូវប្រព្រឹត្តអំពើមិនគប្បីដោយកាយ និងដោយវាចារវាងគ្នានឹងគ្នា ។ យើងនឹងមិនវាយតប់គ្នាទេ›› ។

ដំបូន្មានក្នុងការគ្រប់គ្រងកំណើនប្រពលភាពមានពីរយ៉ាងគឺ៖

* ការដឹងថា កំណើនប្រពលភាពកំពុងកើតមានឡើង យើងអាចចាត់វិធានការកុំឲ្យអធិករណ៍កាន់តែមានកំលាំងខ្លាំងក្លាទៅបាន ។ នៅក្នុងឧទាហរណ៍របស់ព្រះពុទ្ធអង្គ អ្នករំងាប់អធិករណ៍ពោលថា៖ ‹‹យ៉ាងហោចណាស់យើងមិនប្រព្រឹត្តអំពើមិនគប្បីរវាងគ្នានឹងគ្នា.....យើងមិនវាយតប់គ្នា›› ។ ការបញ្ឈប់នូវដំណើរនៃកំណើនប្រពលភាពនឹងផ្ដល់ឱកាសសំរាប់ដោះស្រាយបញ្ហាបានដោយសន្តិវិធី ។

* កាលណាការទាក់ទងគ្នា មានដំណើរក្នុងផ្លូវខុស យើងអាចយកព្រះធម៌ជាសរណៈដើម្បីជជែកពិភាក្សាគ្នាដោយមិត្តភាព និងដោយបែបសាមញ្ញធម្មតា ‹‹អង្គុយកៀកជាប់គ្នា›› ។ តាមព្រះធម៌ ‹‹ភាពញញឹមរាក់ទាក់អាចប្រែធាតុនៃការប្រាស្រ័យទាក់ទងគ្នា›› ។

## ១.៨ ភិក្ខុទាំងឡាយនៅកោសម្ពីបដិសេធដំបូន្មានព្រះពុទ្ធអង្គ

នៅពេលដែលព្រះពុទ្ធអង្គទ្រង់ក្រើនរំលឹកភិក្ខុទាំងឡាយ ដែលប្រណ្ដោះគ្នាឲ្យទៅជាមិត្ត និងឲ្យដោះស្រាយបញ្ហា ដោយជជែកពិភាក្សាគ្នាធម្មតា មតិសំអាងរបស់ភិក្ខុទាំងនោះ បានស្ថិតតាំងនៅជុំវិញចំនុចច្បាស់ជាផ្លូវការ គឺថា តើការបណ្ដេញចេញនូវភិក្ខុជាធម្មកថិកមានសុពលភាព ឬគ្មាន ។

ដោយភិក្ខុវិន័យធរមួយអង្គបានទូលព្រះពុទ្ធអង្គឲ្យទ្រង់អធិប្បាយអំពីសុពលភាពនៃទោសបណ្ដេញ ព្រះពុទ្ធអង្គក៏និមន្តយាងទៅកាន់ពួកគេ ។ ប៉ុន្តែយ៉ាងណាក៏ដោយ នៅពេលដែលព្រះពុទ្ធអង្គទ្រង់ព្រះសំរួលឥរិយាបទនៅអាសនៈ ព្រះពុទ្ធអង្គក៏ទ្រង់សុំឲ្យភិក្ខុរួបរួមគ្នាកុំឲ្យនៅតែប្រណ្ដោះគ្នាយ៉ាងនោះ ។

‹‹ម្នាលភិក្ខុទាំងឡាយល្មមគ្រប់គ្រាន់ហើយ ។ សុំកុំមានវិវាទ កុំមានជំលោះ កុំមានការមិនស្រុះស្រួលគ្នា កុំមានការប្រណ្ដោះគ្នា›› ។

ព្រះពុទ្ធអង្គបានទទួលនូវចំលើយដ៏ចំឡែកមួយ៖ ‹‹ព្រះដ៏មានព្រះភាគ សូមទ្រង់កុំខ្វល់ព្រះទ័យ សូមទ្រង់យាងគង់ដោយសំរួលនៅទីនេះ ក្នុងខណៈនេះពួកទូលបង្គំនឹងទទួលខុសត្រូវចំពោះវិវាទ ជំលោះការមិនស្រុះស្រួលគ្នានេះ›› ។

គឺជាការផ្ទុយពីគំនិតផ្ដួចផ្ដើមរបស់ព្រះពុទ្ធអង្គដែលព្រះអង្គទ្រង់យកព្រះធម៌ទៅអនុវត្តក្នុងអធិករណ៍ ភិក្ខុបានទទូចសុំឲ្យព្រះពុទ្ធអង្គទ្រង់និមន្តយាងចេញទៅសមាធិនៅទីឆ្ងាយ ។ សូមព្រះអង្គទ្រង់កុំបារម្ភនឹង



www.budinst.gov.kh www.elibraryofcambodia.org



ព្រះសំណើរបស់ព្រះពុទ្ធអង្គត្រូវបានច្រានចោលដោយក្រុមទាំងនោះ

www.budinst.gov.kh www.elibraryofcambodia.org

អធិករណ៍ ឬឥទ្ធិពលនៃអធិករណ៍ទៅលើភិក្ខុទាំងឡាយ ។ ដោយពិត វិធីដោះស្រាយជំលោះរបស់ព្រះពុទ្ធអង្គពុំមានលទ្ធផលអ្វីទេ ។ ព្រះពុទ្ធអង្គទ្រង់មានព្រះទ័យចង់បានការផ្លាស់ប្តូរនៃអធិករណ៍ដោយមានមូលដ្ឋានលើព្រះធម៌តាមរយៈការចូលរួមជាមួយស្ថានការណ៍ ។

ព្រះពុទ្ធអង្គទ្រង់បានសាកល្បងជាលើកទី២ ប៉ុន្តែទ្រង់បានជួបប្រទះនូវការបដិសេធដូចជាអ្នកសំរុះសំរួលទូទៅធ្លាប់មានបទពិសោធន៍ដែរ ។ វិធានការនៃជំនឿភាន់ច្រឡំរបស់សហគមន៍ និងការដាក់ព្រះពុទ្ធអង្គឲ្យទ្រង់ស្ថិតនៅឯកោដាច់ពីគេ ពុំមានទេណាមួយយល់ទាស់ទេ ព្រះពុទ្ធអង្គទ្រង់បានទេសនានូវអ្វីដែលគ្មានអ្នកណាចង់ស្តាប់ទេ ។ ឆន្ទៈរបស់ព្រះអង្គចង់បានសន្តិភាព និងឯកភាពនៃគណៈសង្ឃ បានធ្វើឲ្យព្រះអង្គទ្រង់ស្ថិតនៅឆ្ងាយពីភិក្ខុទាំងឡាយ ដែលកំពុងតែ ‹‹ឈ្លោះប្រកែកគ្នា›› ។

## ១.៥ ឧបមាកថាពីរអំពីអធិករណ៍

ព្រះពុទ្ធអង្គទ្រង់ឆ្លើយតបដោយប្រើឧបមាកថាពីរ ។ មួយគឺ ត្រចៀកមួយបានអង្គុយលើដីសាហាវមួយកុំឲ្យជាន់កំទេចសំបុករបស់ខ្លួន (បុព្វជាតិនៃទេវទត្ត) ។

នៅពេលដំរីជាន់កំទេចសំបុក និងកូនតូចៗទាំងអស់ សត្វស្លាបតូចនេះក៏បានរួបរួមជាមួយសត្វដទៃៗធ្វើឲ្យដំរីនោះទទួលមរណៈភាពដោយការឈឺចាប់ ។

‹‹ម្នាលភិក្ខុទាំងឡាយ! ល្មមគ្រប់គ្រាន់ហើយ កុំប្រលោះគ្នាអី›› ព្រោះថា ដោយសារជំលោះ សូម្បីតែកូនត្រចៀកមួយក៏អាចបំផ្លាញជីវិតដំរីមួយបានដែរ›› ។

និទាននេះ មានគោលបំណងនឹងបំភ្លឺនូវគ្រោះថ្នាក់នៃស្ថានការណ៍ដ៏លំបាករបស់ភិក្ខុទាំងឡាយចំពោះសហគមន៍កោសម្ពី និងចំពោះគណៈសង្ឃទាំងមូល ។

ឧបមាកថាទីពីរពាក់ព័ន្ធនឹងអង្គម្ចាស់ទិឃាវុ ដែលមាតាបិតាព្រះអង្គ ត្រូវស្តេចពិម្ពិសារធ្វើឃាតយ៉ាងឃោរឃៅ ។ ដោយលាក់នូវអត្តសញ្ញាណពិតរបស់ខ្លួន កុមារទិឃាវុបានក្លាយទៅជាឆ្មាំក្រោលសត្វនៅក្នុងព្រះបរមរាជវាំងស្តេចពិម្ពិសារ ។ នៅពេលដែលមានឱកាសសំលាប់ស្តេចពិម្ពិសារ ព្រះអង្គម្ចាស់បែរជាអត់ឱនទោសវិញ ។ ដើម្បីជាការតបគុណ ស្តេចពិម្ពិសារ ដែលរន្ធត់ដោយអំពើនេះ បានប្រគល់ដែនដីដែលព្រះអង្គច្បាំងបាន និងលើកបុត្រីរបស់ព្រះអង្គឲ្យទៅជាភរិយាមហេសីនៃព្រះអង្គម្ចាស់នោះទៀតផង ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានបន្តទៀតថា៖

‹‹ឥឡូវម្នាលភិក្ខុទាំងឡាយ ! ប្រសិនបើនេះជាការអត់ទ្រាំ និងជាភាពស្លូតបូតនៃមហាក្សត្រ ដែលកាន់ដាវ តើអ្នកទាំងឡាយគប្បីអត់ទ្រាំ និងស្លូតបូតដល់កំរិតណា ព្រោះអ្នកទាំងឡាយបានចូលជ្រៅទៅក្នុងព្រះធម៌ និងវិន័យនេះទៅហើយ ។

ពោលគឺ បើអ្នកដែលស្ថិតនៅជាប់នឹងអំណាច និង ដែលរស់នៅដោយសារដាវ គេអាចបង្ហាញនូវចិត្តអធ្យាស្រ័យដូចនេះ ។ តើភិក្ខុដែលបានបោះបង់សម្បត្តិលោកិយ គប្បីមានចិត្តសប្បុរសច្រើនយ៉ាងណា ចូរប្រៀបធៀបទៅមើល! ›› ។

អ្នកសំរុះសំរួលច្រើនតែពើបប្រទះនឹងការខកចិត្ត និងការខ្វាចទីចង្អៀតបិទជិតនៃអធិករណ៍ ដែលគេប៉ុនប៉ងចង់ដោះស្រាយ ពិសេសនៅពេលគេឃើញថា លទ្ធភាពនៃសន្តិភាពកំពុងកន្លងផុតទៅ ។ ថ្វីបើបានត្រាស់ដឹង និងលះបង់កិលេសអស់ហើយក៏ដោយ ព្រះពុទ្ធអង្គទ្រង់មានការឈឺចាប់នឹងសាវ័ករបស់ទ្រង់ដែលបដិសេធទ្រង់ ។ តាមអត្ថបទឯកសារព្រះពុទ្ធអង្គទ្រង់មានព្រះតំរិះថា៖



www.budinst.gov.kh www.elibraryofcambodia.org



ព្រះធម៌ទេសនាអំពីដំណើររឿងសត្វក្រួច និងសត្វដំរី

‹‹ក្នុងលក្ខខ័ណ្ឌបច្ចុប្បន្ន គថាគតមានការចង្អៀតចង្អល់ និងទើសទាល់ ព្រមទាំងមានជីវិតប្រកបដោយភាពមិនស្រួល ។ លើសពីនេះទៅទៀត ភិក្ខុសង្ឃទាំងឡាយនោះមិនចាប់អារម្មណ៍ចំពោះអ្វី ដែលតថាគតបានពោលទេ ។ គេទាំងឡាយមានអារម្មណ៍ជាប់ជំពាក់ ហើយមិនងាយនឹងបញ្ចុះបញ្ចូលគេទេ ឧបមាថា តថាគតត្រូវថយចេញពីហ្វូងមនុស្ស ហើយទៅរស់នៅក្នុងភាពជាឯកោវិញ›› ។ ព្រះអង្គទ្រង់ចាកចេញពីអាសនៈ រួចនិមន្តយាងចេញទៅ ។

## ១.១០ ចំណាកចេញពីកោសម្ពី

អត្ថបទវិន័យក្នុងធម្មទេសនាមួយ ដែលសំដែងថា សកម្មភាពអធិករណ៍គឺជាអកុសលកម្ម ដែលមានទំនោរនឹងផ្ទុះកាន់តែខ្លាំងឡើងដោយវិធីតបទៅវិញទៅមក ហើយអះអាងថា មានតែការផ្លាស់ប្តូរផ្នែកស្មារតីទេ ទើបអាចនាំមកនូវសន្តិភាព ។

នៅពេលណា ដែលមានការវាយតប់ ទាំងអស់គ្នាគ្មាននរណាម្នាក់មានអារម្មណ៍ថា ‹‹អាត្មាអញបានរួមចំណែកក្នុងនេះដែរទេ›› ។

គេបានបំភ្លេចចោលនូវសំដី ដែលប្រកបដោយគតិបណ្ឌិត ។ គេពោលដោយភ្លេចស្មារតី ពោរពេញទៅដោយពាក្យមិនល្អ ហើយមិនដឹងថាអ្វីដែលដឹកនាំគេឲ្យធ្វើរឿងឈ្លោះឡើយ ។

កោធៈមិនអាចរលត់នៅក្នុងគំនិតនៃអ្នកដែលនៅតែគិតថា ‹‹អ្នកនោះបានរំលោភ បានធ្វើឲ្យអាត្មាអញឈឺចាប់›› បានទេ ។

ទោសៈមិនអាចរំងាប់ដោយទោសៈបានទេ មានតែអទោសៈ ដែលរំងាប់នូវការវិលមកវិញនូវទោសៈបាន ។ នេះគឺជាវិធានដ៏អមតៈ ។

‹‹ត្រាច់ទៅម្នាក់ឯងប្រសើរជាងត្រាច់ទៅជាមួយពួកពាល ។ ត្រាច់ទៅតែឯងមិនពាក់ព័ន្ធជាមួយនរណាមិនធ្វើអំពើអាក្រក់ ដូចដំរីស្ទាវនៅក្នុងព្រៃស្រោង›› ។

ក្រោយពីទ្រង់និមន្តយាងបិណ្ឌបាត្រនៅកោសម្ពី និងដោយមិនបានលាគណៈភិក្ខុសង្ឃ ព្រះពុទ្ធអង្គទ្រង់យកបាត្រ និងត្រៃចីវរ ហើយក៏ទ្រង់ចាកចេញពីកោសម្ពីតែមួយអង្គឯងគត់ ។ រឿងហេតុ ដែលព្រះពុទ្ធអង្គពុំមានសង្ឃជាពុទ្ធសាវ័កនិមន្តតាមនេះគឺជារឿងមួយគួរឲ្យចាប់អារម្មណ៍ ។ នេះជាការពិតណាស់តាមព្រះត្រៃបិដក នេះគឺជាឱកាសតែមួយគត់ ដែលព្រះពុទ្ធអង្គយាងចេញទៅណាមកណាតែមួយអង្គឯង (លើកលែងតែនៅពេលដែលព្រះអង្គពុំទាន់រៀបចំគណៈសង្ឃ) ។

ព្រះពុទ្ធអង្គនិមន្តយាងចេញពីកោសម្ពីមួយអង្គឯង ដោយទ្រង់ពុំបានលាអ្នកណាទាំងអស់ ។ ព្រឹត្តិការណ៍នេះជាសារលិខិតបញ្ជាក់ចំពោះភិក្ខុសង្ឃទាំងឡាយថា ជាស្ថានការណ៍មួយដ៏ធ្ងន់ធ្ងរ ហើយរហូតមកដល់ពេលនេះ ពាក្យសំដីមិនអាចពាំនាំទៅបានទេ ។

នៅពេលដែលពុទ្ធបរិស័ទ និងអ្នកស្រុកដែលរស់នៅជុំវិញវត្តបានទទួលដំណឹងពីការចាកចេញនៃព្រះសម្មាសម្ពុទ្ធ ពួកគេក៏សាកសួរអំពីដំណើរដើមទងដែលនាំអោយព្រះអង្គចាកចេញលឿនបែបនេះ ។ ពួកគេមិនសប្បាយចិត្តនឹងចំលើយដែលគេបានទទួលទេ ។

អ្នកស្រុកបានសួរថា៖ ‹‹បពិត្រលោកម្ចាស់ទាំងឡាយ តើលោកម្ចាស់ចង់មានពុទ្ធដិកាថា ក្រោយបានទទួលផ្នួសជាភិក្ខុ នៅក្នុងសំណាក់ព្រះពុទ្ធរួចហើយ លោកម្ចាស់ទាំងឡាយលែងទទួលដំបូន្មានរបស់ព្រះអង្គឬ?›› ។

សង្ឃមួយអង្គឆ្លើយថា៖ ‹‹ជាការពិតហើយ›› ។ រួចអ្នកស្រុកក៏បាននិយាយទៅកាន់គ្នាថា៖ ‹‹ភិក្ខុទាំង



www.budinst.gov.kh www.elibraryofcambodia.org



អ្នកស្រុកភូមិបានបដិសេធមិនប្រគេនចង្ហាន់ដល់ព្រះសង្ឃប្រឈ្លោះគ្នាទាំងនោះ

www.budinst.gov.kh www.elibraryofcambodia.org

ឡាយនោះមិនមានឆន្ទះដោះស្រាយអធិករណ៍ នៅពេលដែលព្រះបរមគ្រូទ្រង់បានស្នើសុំឲ្យដោះស្រាយទេ ។ នេះគឺជាកំហុសរបស់ភិក្ខុទាំងអស់ ដែលនាំឲ្យយើងខកខានមិនបានជួបព្រះភក្ត្រព្រះបរមសាស្តា ។ ចាប់ពីពេលនេះតទៅយើងនឹងលែងផ្តល់ទិរាសនៈចង្ហាន់ ឬគោរពភិក្ខុទាំងនោះទៀតហើយ›› ។

អ្នកស្រុកឈប់ដាក់បាត្រ ភិក្ខុទាំងឡាយស្រេកឃ្លាន ហើយភិក្ខុទាំងនេះត្រូវប្រើរយៈពេលតែពីរបីថ្ងៃប៉ុណ្ណោះ ដើម្បីកែច្នៃស្ថានការណ៍ឲ្យបានប្រសើរឡើងវិញ ។ ការដែលព្រះពុទ្ធអង្គដកព្រះកាយចេញពីស្ថានការណ៍នោះ បាននាំឲ្យភិក្ខុទាំងឡាយប្រឈមមុខនឹងផលវិបាកនៃអធិករណ៍ ហើយក៏បានធ្វើឲ្យភិក្ខុទាំងនោះត្រឡប់មករកការត្រូវគ្នាវិញ ។ ជាទីបញ្ចប់ភិក្ខុទាំងឡាយបានសុខចិត្តពីភាក្យគ្នា និងសុំទោសគ្នាទៅវិញទៅមក ។

ភ្លាមៗនោះ ភិក្ខុទាំងឡាយបានប្រាប់អ្នកស្រុកថា លោកបានបង្កបង្កើតឡើងនូវរឿងធំណោះនេះ ។

ភិក្ខុទាំងឡាយបានពោលទៅកាន់អ្នកស្រុកថា៖ ‹‹ញោម! អាត្មាភាពទាំងអស់គ្នា បានស្រុះស្រួលជាមួយគ្នាវិញហើយ សូមជួយឧបត្ថម្ភអាត្មាភាពដូចកាលពីមុនផង›› ។ ប៉ុន្តែអ្នកស្រុកមិនយល់ព្រមភ្លាមៗទេ ‹‹បពិត្រលោកម្ចាស់ទាំងឡាយ តើលោកម្ចាស់បានសុំខមាទោសពីព្រះបរមគ្រូហើយឬនៅ?›› ។

‹‹នៅទេ››

‹‹ដូច្នេះសូមលោកម្ចាស់សុំខមាទោសពីព្រះបរមគ្រូទៅ ។ នៅពេលដែលយើងខ្ញុំព្រះករុណាបានដំណឹងថា ព្រះបរមគ្រូបានអត់ឱនទោសឲ្យលោកម្ចាស់ហើយ យើងខ្ញុំព្រះករុណានឹងឧបត្ថម្ភព្រះតេជគុណដូចកាលពីមុន›› ។

ប៉ុន្តែដោយសាររដូវភ្លៀងបានចាប់ផ្តើម (ដែលត្រូវនឹងខែ ដែលភិក្ខុសង្ឃចូលវស្សា) ភិក្ខុសង្ឃទាំងនោះមិនអាចនិមន្តទៅសុំខមាលទោសពីព្រះពុទ្ធអង្គបានទេ ។ ដោយប្រការនេះ ក៏គង់នៅចាំវស្សាដោយមិនសុខស្រួលនៅកោសម្ពីនោះទៅ ។

## ១.១១ ដំណើរនិមន្តយាងមករកសង្ឃដែលរស់នៅដោយចុះសំរុងគ្នា

ក្រោយពីទ្រង់បានចាកចេញពីកោសម្ពី ព្រះពុទ្ធអង្គទ្រង់បានជួបនឹងបុព្វជិតភគុ ដែលជាភិក្ខុធុតង្គរស់នៅម្នាក់ឯង ។ ព្រះតេជគុណភគុបានធ្វើបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅចំពោះព្រះពុទ្ធអង្គ ហើយបានបញ្ជាក់ថា លោកទទួលចង្ហាន់បិណ្ឌបាត្រគ្រប់គ្រាន់ ផុយពីភិក្ខុសង្ឃទាំងឡាយនៅកោសម្ពី ។ នៅតាមផ្លូវព្រះពុទ្ធអង្គទ្រង់បានជួបសួរសុខទុក្ខចំពោះភិក្ខុបីអង្គគឺ អនុរុទ្ធ និន្ទិយៈ និងកិម្ពលៈ ដែលគង់ចាំវស្សានៅព្រៃឫស្សីផ្នែកខាងកើត ។ ព្រះពុទ្ធអង្គទ្រង់សួរថា តើលោកទាំងនោះបានរស់នៅដោយសុខស្រួលជាមួយគ្នា ឬយ៉ាងណា ហើយព្រះអង្គបានទទួលចំលើយដូចតទៅ៖

‹‹បពិត្រព្រះអង្គដ៏ចំរើន›› ទូលបង្គំទាំងអស់គ្នារស់នៅជាមួយគ្នាសុខស្រួល និងល្អកល្អើនពន់ពេកណាស់ដូចទឹក និងត្រី ហើយទុកដាក់គ្នាទៅវិញទៅមក ដោយសេចក្តីស្រឡាញ់›› ។

ព្រះពុទ្ធអង្គទ្រង់សួរថា៖ ‹‹ម្នាលអនុរុទ្ធថាតើអ្នករស់នៅយ៉ាងណា....ដោយមានចក្ខុសម្លឹងមើលគ្នាដោយសេចក្តីស្រឡាញ់?›› ។

ព្រះតេជគុណអនុរុទ្ធបានទូលតបថា៖ ‹‹បពិត្រព្រះដ៏មានព្រះភាគ ទូលព្រះបង្គំយល់ថា គឺជាអភ័យឯកសិទ្ធិមួយ ដែលបានមករស់នៅជាមួយសាវ័កដ៏ល្អនៃព្រះធម៌ ។ ការរស់នៅនេះបានដឹកនាំទូលព្រះបង្គំឲ្យមានមេត្រីភាពទាំងនៅក្នុងចិត្ត និងក្នុងកាយវាចា


www.budinst.gov.kh www.elibraryofcambodia.org

ចំពោះពួកគេ ។ ជាការពិតណាស់ ទូលព្រះបង្គំមិនចាំបាច់ធ្វើអ្វីឲ្យប្លែកពីគេទេ ពីព្រោះយើងទាំងអស់គ្នារស់នៅទៅតាមព្រះធម៌ ។ បពិត្រព្រះដ៏មានព្រះភាគ ទូលបង្គំទាំងអស់គ្នាមានកាយផ្សេងគ្នាមែន ប៉ុន្តែមានចិត្តតែមួយគត់›› ។

ព្រះពុទ្ធអង្គទ្រង់សួរបន្តថា៖ ‹‹សូមប្រាប់តថាគតមើល តើអស់លោករស់នៅយ៉ាងណាដែលថា តាំងចិត្តមាំនៅក្នុងព្រះធម៌?›› ។

ព្រះអនុរុទ្ធទូលតបថា៖ ‹‹បពិត្រព្រះដ៏មានព្រះភាគ ក្នុងចំណោមទូលព្រះបង្គំទាំងអស់គ្នា អង្គណាមួយត្រឡប់ពីបិណ្ឌបាត្រតាមភូមិដល់មុនគេ អង្គនោះត្រូវរៀបចំទីអាសនៈ ដងទឹកទុកសំរាប់លាងជើង ទំរជើង ជើងតាំង ។ ក្រោយលាងចាន និងយកចេញមករៀបហើយ អង្គនោះយកទឹកសំរាប់ឆាន់ និងទឹកសំរាប់ប្រើ មករៀបចំទៀត ។ អង្គឯណាត្រឡប់មកក្រោយគេបង្អស់ អង្គនោះត្រូវរៀបចំទុកដាក់អាហារដែលនៅសល់ និងរៀបចំទីអាសនៈ ទំរជើង និងដាក់បាត្រទៅតាមកន្លែងរបស់វា ។បន្ទាប់មកយើងអង្គុយចុះពិភាក្សាអំពីព្រះធម៌រៀងរាល់យប់›› ។

របៀបរស់នៅដោយមិនគិតពីប្រយោជន៍ខ្លួនឯង(អនត្តទត្ថៈ)គឺជាការផ្ទុយគ្នាស្រឡះនឹងការរស់នៅដោយឈ្លោះគ្នា ក្តុងក្តាំង និងទទើសទទែង នៅក្នុងវត្តអារាមបែបអត្តទត្ថៈ ។ ដោយសារតែរបៀបទង់ល្អប្រសើរ ភិក្ខុទាំងបីអង្គនេះ បានទទួលគុណប្រយោជន៍អំពីដំបូន្មានរបស់ព្រះពុទ្ធអង្គ ដែលជាការផ្ទុយគ្នាស្រឡះទៅនឹងប្រតិកម្មនៃភិក្ខុសង្ឃនៅកោសម្ពី ដែលមិនប្រកបដោយគន្លងនៃព្រះសម្មាសម្ពុទ្ធ›› ។

ព្រះពុទ្ធអង្គបានយាងបន្តទៅបារិលេយ្យ នៅទីនោះ ព្រះអង្គគង់នៅក្រោមដើមឈើមួយ ហើយធ្វើសមាធិ ដោយគិតរំពឹងដូច្នេះ៖

‹‹កាលពីដើមរំខានទៅដោយភិក្ខុសង្ឃទាំងឡាយនៅកោសម្ពី ដែលជាអ្នកបង្កវិវាទ បង្កជំលោះ ...ប្រឈ្លោះគ្នា...វាយតប់គ្នា...បញ្ហាស្របច្បាប់នៅក្នុងគណៈសង្ឃ តថាគតមិនបានគង់នៅដោយសុខស្រួលទេ ។ ប៉ុន្តែឥឡូវ តថាគតមកគង់នៅតែមួយអង្គឯងគ្មានអ្នកដទៃ តថាគតកំពុងគង់នៅដោយសុខស្រួលឃ្លាតចាកពីភិក្ខុសង្ឃទាំងឡាយនោះ ដែលជាអ្នកបង្កវិវាទ...ក្នុងគណៈសង្ឃ›› ។

នៅពេលព្រះអង្គទ្រង់ត្រិះរិះយ៉ាងនេះ ដំរីមួយហ្វូងបានចេញមករុញ និងច្រានគ្នាទៅវិញទៅមក ធ្វើឲ្យទឹកអូរឡើងកករល្អក់ ។ ដូចគ្នានេះដែរ ដោយសារយើងចូលរួមក្នុងការឈ្លោះទាស់ទែងគ្នា យើងបង្ខូចនូវបរិដ្ឋានសង្គម ដែលយើងរស់នៅ ។ ដំរីធំ ដែលដឹកនាំហ្វូងដំរីនោះ បានចាកចេញពីហ្វូង ហើយយកទឹកមកថ្វាយព្រះអង្គសោយ និងបានជាន់ស្មៅនៅជុំវិញព្រះអង្គឲ្យរាបស្មើ ។ នៅពេលវាធ្វើបែបនេះ ដំរីស្តេចត្រិះរិះថា តើវាកាន់តែសប្បាយយ៉ាងណា ដោយឥឡូវវាបានចាកចេញពីហ្វូងនោះផុតមក ។ ដោយទ្រង់ប្រមើលឃើញគំនិតដំរី ព្រះពុទ្ធអង្គទ្រង់ញញឹម ហើយទ្រង់ធ្វើការសង្កេតថា៖ ‹‹យើងទាំងពីរយល់ពីតំលៃជីវិតឯកោនៅក្នុងព្រៃ›› ។

## ១.១២ សង្ឃទាំងឡាយនិមន្តទៅសាវត្ថី

នៅកោសម្ពី ព្រះសង្ឃដែលស្រេកឃ្លានក្រោយពេលចូលវស្សា ដោយមានចង្អាន់ដ៏តិចតួចនិងដោយទទួលការមើលងាយប្រចាំថ្ងៃពីអ្នកស្រុក ។ នៅទីបញ្ចប់ក៏បាននិមន្តជួបនឹងព្រះពុទ្ធអង្គ នៅពេលព្រះអង្គនិមន្តយាងត្រឡប់ទៅសាវត្ថី ។ ដោយបានទទួលរបាយការណ៍ថា ភិក្ខុសង្ឃទាំងឡាយនោះបាននិមន្តជិតទៅដល់ទីក្រុង ព្រះមហាក្សត្រនគរកុសិនារាទ្រង់



www.budinst.gov.kh www.elibraryofcambodia.org



ព្រះពុទ្ធអង្គសំដែងនូវការអាណិតអាសូរ និងទទួលស្វាគមន៍សង្ឃទាំងនោះ

www.budinst.gov.kh www.elibraryofcambodia.org

បានផ្ដល់កិច្ចការពារថ្វាយព្រះសម្មាសម្ពុទ្ធ ដោយរាំង មិនឲ្យភិក្ខុសង្ឃទាំងនោះចូលក្នុងទីក្រុង ។ ចំលើយរបស់ព្រះសម្មាសម្ពុទ្ធជាចំលើយប្រកបដោយសប្បុរសធម៌ និងករុណាធម៌ ។

‹‹បពិត្រព្រះដ៏មានព្រះភាគ ទូលព្រះបង្គំមិនអនុញ្ញាតឲ្យសង្ឃទាំងនោះចូលមកក្នុងនគររបស់ទូលបង្គំទេ›› ។

‹‹បពិត្រមហារាជ ភិក្ខុសង្ឃទាំងនោះជាមនុស្សល្អ ។ គ្រាន់តែដោយសារជំលោះ គេមិនចាប់អារម្មណ៍ចំពោះពាក្យទូន្មានរបស់តថាគត ។ ឥឡូវគេមកសុំខមាលទោសពីតថាគត ។ សូមមហារាជឲ្យគេចូលមក មហាក្សត្រ›› ។

ទៅពេលដែលនិមន្តតំរង់ទៅរាជវាំង ព្រះភិក្ខុសង្ឃពីកោសម្ពី មានសភាពគួរឲ្យអាណិតអាសូរ ស្គមនិងស្រេកឃ្លាន ព្រមទាំងពេញទៅដោយការអៀនខ្មាស ។ ភិក្ខុសង្ឃទាំងនោះនិមន្តទៅដោយមានអ្នកស្រុកចង្អុលបង្ហាញគ្នីគ្នាទៅវិញទៅមក ។ អ្នកនៅក្នុងរាជវាំងបានទូលសួរព្រះពុទ្ធអង្គថា តើពួកគេគប្បីធ្វើយ៉ាងណា ចំពោះភិក្ខុសង្ឃកោសម្ពីទាំងឡាយនោះ?

‹‹តើទូលព្រះបង្គំទាំងឡាយ គប្បីប្រគេនចង្ហាន់ដល់ភិក្ខុអង្គណាខ្លះ និងមិនប្រគេនដល់អង្គណាខ្លះទៅ បពិត្រព្រះដ៏មានព្រះភាគ?›› ។

ព្រះពុទ្ធអង្គមានព្រះបន្ទូលតបវិញថា៖ ‹‹មិនត្រូវរើសអើងដល់ភិក្ខុអង្គណាទេ›› ។

‹‹អ្នកគប្បីប្រគេនចង្ហាន់ទៅភាគីទាំង២ និងស្ដាប់ធម៌នៃភាគីទាំងពីរ›› ។

ព្រះពុទ្ធអង្គទ្រង់មិនបានបង្ខិតបង្ខំតាមផ្លូវចិត្តបែបណាមួយទេ ។ តាមពិតភិក្ខុទាំងនោះនិមន្តមកដល់រាជវាំងដោយមិនហ៊ានងើបព្រះកេស ព្រោះមានការអៀនខ្មាស ។ ភិក្ខុទាំងអស់បានលុតជង្គង់ទៅទាបព្រះបាទាព្រះសម្មាសម្ពុទ្ធ ហើយបានសុំខមាទោសពីព្រះអង្គ ។

## ១.១៣ ការផ្សះផ្សារ

ភិក្ខុជាធម្មកថិកបានគិតពីគ្រប់រឿងរ៉ាវដែលកើតឡើង ហើយត្រិះរិះថា៖ ‹‹នេះជាអាបត្តិ...អាត្មាអញបានធ្វើខុស ។ អាត្មាអញត្រូវបានបណ្ដេញចេញដោយមានការកាត់ទោសត្រឹមត្រូវ ហើយដែលមានសុពលភាពតាមច្បាប់›› ។ ផ្ទុយទៅនឹងអ្វីដែលយើងបានរំពឹងទុក ភិក្ខុជាធម្មកថិកពុំបាននិមន្តទៅរកព្រះពុទ្ធអង្គដោយផ្ទាល់ទេ ប៉ុន្តែព្រះអង្គបានបញ្ជូនសិស្សគណរបស់លោកឲ្យនិមន្តទៅទទូលដំបូន្មានព្រះពុទ្ធអង្គ ថាតើបញ្ហានេះត្រូវដោះស្រាយយ៉ាងណាហើយ? ព្រះពុទ្ធអង្គទ្រង់ឆ្លើយតបក្នុងន័យប្ដូរអារម្មណ៍ពីការស្ដីបន្ទោសដោយមកពីអំពើក្នុងអតីតកាល ទៅជាដំណោះស្រាយក្នុងអនាគតកាល៖

‹‹ម្នាលភិក្ខុទាំងឡាយ នេះជាអាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែដោយហេតុថា ភិក្ខុ ដែលមានកំហុស ហើយដែលត្រូវបណ្ដេញចេញ បានមើលឃើញនូវអាបត្តិ ដូចនេះភិក្ខុគប្បីត្រូវបញ្ចូលដូចដើមវិញ›› ។

ភិក្ខុជាសិស្សផ្នែកធម្មៈ បានចូលទៅជិតភិក្ខុជាសិស្សផ្នែកវិន័យ ដើម្បីស្នើសុំបញ្ចូលភិក្ខុជាធម្មកថិកទៅកន្លែងដើមវិញ ដោយពោលថា៖ ‹‹បពិត្រលោកដ៏មានអាយុទាំងឡាយ ឥឡូវយើងត្រូវសំរេចជាឯកច្ឆន្ទនៅក្នុងគណៈសង្ឃ ដើម្បីបញ្ចប់ករណីនេះ›› ។

ក្រុមសមណសិស្សផ្នែកវិន័យបាននិមន្តទៅទូលសួរព្រះសម្មាសម្ពុទ្ធ អំពីវិធីសមស្របដើម្បីបញ្ចប់ជំលោះ ហើយព្រះពុទ្ធអង្គទ្រង់ឆ្លើយតបថា គណៈសង្ឃទាំងមូលនៅកោសម្ពី ពុំមែនគ្រាន់តែភិក្ខុទាំងឡាយផ្នែកវិន័យ



www.budinst.gov.kh www.elibraryofcambodia.org

ទេ គប្បីចូលរួមទាំងអស់គ្រប់អង្គក្នុងការចូលរួមធ្វើសេចក្តីសំរេចចិត្តនេះ ។ ‹‹ភិក្ខុគ្រប់រូប ទោះបីជាឈឺក៏គប្បីរួមប្រជុំទាំងអស់ ពុំមានអង្គណាអវត្តមានទេ ។ នៅពេលជួបជុំគ្រប់អង្គហើយ គណៈសង្ឃទាំងមូលត្រូវបានទទួលពត៌មានអំពីភិក្ខុដែលមានសមត្ថភាព និងមានបទពិសោធន៍មួយអង្គ ដែលពោលថា៖ ‹‹ព្រះតេជគុណគ្រប់អង្គ ភិក្ខុនេះបានប្រព្រឹត្តខុស ហើយបានទទួលទោសបណ្តេញចេញ ប៉ុន្តែលោកបានឃើញកំហុសហើយបានកែខ្លួន ។ បើគណៈសង្ឃយល់ថាជាការត្រឹមត្រូវ គណៈសង្ឃគប្បីសំរេចជាឯកច្ឆន្ទ ដើម្បីដោះស្រាយបញ្ហារបស់លោក ។ នេះជាញត្តិ....បើការសំរេចជាឯកច្ឆន្ទនេះធ្វើឲ្យព្រះតេជគុណគ្រប់អង្គពេញព្រះទ័យ សូមព្រះតេជគុណនៅស្ងៀម›› ។ អង្គណាមិនពេញព្រះទ័យគប្បីមានពុទ្ធដិកា ។ ភាពជាឯកច្ឆន្ទ...បានសំរេច ។ ការបាក់បែកសង្ឃភេទត្រូវបានបញ្ចប់ ។ ករណីនេះធ្វើឲ្យគ្រប់អង្គមានព្រះទ័យជ្រះថ្លា ដូច្នេះគ្រប់អង្គបានគង់នៅស្ងៀម›› ។ ពិធីនេះអាចធ្វើឡើងម្តងទៀត ដោយមានសូត្របាតិមោក្ខផង ។

## ១.១៤ គុណសម្បត្តិដែលអ្នកសំរុះសំរួលគប្បីមាន

.................................................

ក្នុងចំលើយតបទៅនឹងសំនួររបស់ឧបាលី ព្រះពុទ្ធអង្គទ្រង់បញ្ជាក់ថា៖ ‹‹ដំបូងភាពជាឯកច្ឆន្ទ ពុំមានសុពលភាពផ្នែកច្បាប់ទេ លើកលែងតែគណៈសង្ឃបានធ្វើការស្រាវជ្រាវ ហើយ ‹‹រកឃើញហេតុបច្ច័យនៃបញ្ហា›› បន្ទាប់មកភាពជាឯកច្ឆន្ទគប្បីធ្វើឡើង ‹‹ក្នុងស្មារតី››នៃការព្រមព្រៀងពិតៗ សមស្របទៅតាមព្រះធម៌ ពុំមែនគ្រាន់តែជាភាពឯកច្ឆន្ទនៃក្រុមតូចមួយក្នុងគណៈសង្ឃទេ›› ។

តទៅនេះគឺការពណ៌នាអំពីប្រភេទនៃភិក្ខុ ដែលអាចដោះស្រាយអធិករណ៍នៅក្នុងគណៈសង្ឃ ។ គុណសម្បត្តិមួយចំនួន ដែលពណ៌នា មានការពាក់ព័ន្ធយ៉ាងច្បាស់ទៅនឹងមុខនាទីនៃអ្នកសំរុះសំរួល ។ តទៅនេះគឺជាពុទ្ធដិការបស់ព្រះភិក្ខុឧបាលិ៖ ‹‹នៅក្នុងកិច្ចការ និងការសំរេចនៃគណៈសង្ឃ ហើយនិងក្នុងបញ្ហាដែលតំរូវឲ្យមានការស៊ើបអង្កេត តើមនុស្សប្រភេទយ៉ាងដូចម្តេច ដែលគេត្រូវការជាងគេ? តើភិក្ខុមួយអង្គ ដែលស័ក្តិសមជាអ្នកដឹកនាំនៅទីនេះ ត្រូវមានលក្ខណៈយ៉ាងណា?

ក/ដំបូងបង្អស់គឺត្រូវមានសីលធម៌ល្អឥតខ្ចោះ មានចរិតឥតសៅហ្មង មានឥន្ទ្រីយ៍សង្រួមបានល្អ ។

បន្ទាប់មក គុណសម្បត្តិដំបូងបង្អស់នៃអ្នកសំរុះសំរួល គឺត្រូវរស់នៅប្រកបដោយសតិសម្បជញ្ញៈ ហើយកិច្ចការផ្ទាល់ខ្លួនត្រូវមានរបៀបរៀបរយល្អ ។

ខ/គូបដិបក្ខទាំងឡាយមិនចាប់ពិរុទ្ធលោកចំពោះផ្លូវវិន័យ ពីព្រោះគេគ្មានអ្វីនឹងនិយាយប្រឆាំងលោកទេ ។

អ្នកសំរបសំរួលគប្បីរស់នៅយ៉ាងណាឲ្យផុតពីការស្តីបន្ទោសនៃគូជម្លោះគ្នាណាមួយ ហើយដែលគេមិនអាចងាយស្រួលនឹងគំរាមកំហែង ឬបង្ខូចកេរ្តិ៍ឈ្មោះ ។

គ/គូបដិបក្ខស្ថិតនៅក្រោមការត្រួតត្រារបស់លោក ហើយប្រជាជននៅក្រោមការអប់រំរបស់លោក ។

អ្នកសំរបសំរួលត្រូវចេះនិយាយឲ្យបានច្បាស់លាស់ និងដោយមានអំណាចផ្នែកសីលធម៌ កាលណាសេចក្តីត្រូវការកើតឡើង ។

ឃ/ហើយលោកមិនខ្វះខាតនឹងជំនឿរបស់លោកផ្ទាល់ (ប៉ុនប្រសប់)ទាំងចោទសំនួរ និង ផ្តល់ចំលើយមិនឲ្យមានការឈឺចាប់ និងចិះពាល់ ។



www.budinst.gov.kh www.elibraryofcambodia.org

អ្នកសំរបសំរួលគប្បីប្រើជំនាញចោទសួរ «ដោយមិនផ្ដល់នូវការឈឺចាប់» ហើយការត្រួតត្រាដែលលោកអនុវត្តពុំមែនជាប្រភេទបង្ខិតបង្ខំទេ ។ នៅក្នុងស្ថានការណ៍កោសម្ពី យើងបានឃើញថា ថ្វីបើព្រះអង្គមានការខកចិត្តនឹងរឿងកំប៉ិចកំប៉ុកនៃភិក្ខុទាំងឡាយក៏ដោយ ក៏ព្រះពុទ្ធអង្គទ្រង់មានជំនឿជឿជាក់ទៅលើការអនុវត្តន៍នៃព្រះធម៌ដ៏ជំនាញ និងទៅលើការដោះស្រាយនូវស្ថានការណ៍ ។

ង/អាចបំពេញតួនាទីជាអ្នកនាំសារ

អ្នកសំរបសំរួលត្រូវមានលទ្ធភាពអាចពាំនាំនូវចំលើយពីភាគីជំលោះមួយទៅមួយបានដោយត្រឹមត្រូវ ។

ច/បានទទួលពត៌មានច្បាស់លាស់នូវអ្វី ដែលគេប្រាប់លោកអំពីកិច្ចការរបស់គណៈសង្ឃ ។

អ្នកសំរបសំរួលត្រូវស្គាល់ច្បាស់ពីប្រវត្តិ និងពត៌មានលំអិតផ្សេងទៀតពីភាគីទំនាស់ ។

ឆ/បញ្ជូនទៅដោយក្រុមភិក្ខុសង្ឃដែលលោកស្ដាប់បង្គាប់ ប៉ុន្តែលោកពុំគិតថា «ខ្ញុំកំពុងធ្វើការនេះ» ទេ ។

ដោយការសំរុះសំរួលមានសារៈសំខាន់ខ្លាំងចំពោះប្រជាជន និងចំពោះព្រឹត្តិការណ៍ គេមានចេតនានឹងគិតថា ខ្លួនគេជា «អ្នកសំរបសំរួលដ៏អស្ចារ្យ» ដើម្បីលើកតំកើងរូបភាពរបស់ខ្លួន ។ អត្តមាយាផ្ទះផ្ទួនអាចជ្រៀតជ្រែកជាមួយកិច្ចការដ៏ហ្មត់ចត់ និងប្រុងប្រយ័ត្ននៃការនាំសារ ឲ្យពើបប្រទះនឹងគ្រោះថ្នាក់ ។

ជ/ទោះបីគេធ្លាក់ទៅក្នុងរឿងពិរុទ្ធក៏ដោយ ទោះបីជាកំហុសបែបណាក៏ដោយ និងទោះបីដោះស្រាយបែបណាក៏ដោយ ការវិភាគទាំងពីរនេះត្រូវបានប្រគល់ឲ្យដល់លោក លោកជាអ្នកមានជំនាញក្នុងរឿងអាបត្តិ និងក្នុងរឿងដោះស្រាយ ។

ដោយត្រូវបានបញ្ជូនទៅ និងមានទំលាប់ល្អលោកចេញទៅដោយភ្ជាប់ជាប់កិច្ចការទាំងនេះ ។ លោកត្រូវបានគេបញ្ជូនទៅហើយ តើមានអ្វីជាហេតុបច្ច័យ? នោះគឺការធ្វើឲ្យមនុស្សម្នាក់មានឋានៈដូចដើមវិញ ដោយគេបានបញ្ចប់រួចហើយនូវរឿងនេះ លោកក៏ដឹងរឿងនេះដែរ មានជំនាញពីព្រោះលោកកំពុងស្ថិតនៅក្នុងការវិភាគ ។

ការសំរុះសំរួលក្នុងរឿងវិវាទ ដែលពាក់ព័ន្ធនឹងច្បាប់ តំរូវឲ្យអ្នកសំរុះសំរួលមានចំណេះដឹងផ្នែកច្បាប់ ។ ពាក្យយោងដែលថា៖ «ត្រូវបានបញ្ជូនទៅ និងអ្វីជាហេតុបច្ច័យ» អាចបញ្ជាក់នូវចំណេះដឹងអំពីអ្វី ដែលទាមទារដំណោះស្រាយតាមផ្លូវច្បាប់ ។ (ដូចក្នុងករណីនេះ ដែលពាក់ព័ន្ធទៅនឹងការបណ្ដេញចេញនូវភិក្ខុជាធម្មកថិក) ឬគេស្នើឲ្យអ្នកសំរុះសំរួលខ្លួនឯងគប្បីមានអំណាចខ្លះដាក់ចេញនូវដំណោះស្រាយ» ។

ឈ/ដោយគោរពចំពោះមហាថេរ ចំពោះភិក្ខុទើបនឹងបួសថ្មី ចំពោះចាស់ទុំ និងចំពោះអ្នក ដែលមានវ័យមធ្យម អ្នកជួយដល់មនុស្សជាច្រើន និងឈ្លាសវៃក្នុងកិច្ចការនេះ «ភិក្ខុដូចនេះសមល្មមនឹងធ្វើជាអ្នកដឹកនាំបាន» ។

អ្នកសំរុះសំរួលគប្បីទាក់ទងស្មើគ្នាជាមួយភាគីជំលោះ ដែលមានឋានៈផ្សេងៗគ្នាដោយក្ដីគោរព និងករុណា ។ នេះមានសារៈសំខាន់ជាពិសេស ព្រោះភាគីជំលោះមានទំនោរចង់គេងប្រវ័ញ្ច ឬឆក់ឱកាសដោយភាពខុសគ្នានៃតួនាទី នៅក្នុងអធិករណ៍ច្រើនជាងនៅក្នុងជីវិតធម្មតា ។

## ១.១៥ សេចក្ដីសង្ខេប

ដំណើរកសាងសន្តិភាពច្រើនប្រព្រឹត្តទៅមិនបានល្អកល្អើនទេ ។ នៅទីនេះយើងឃើញព្រះពុទ្ធអង្គទ្រង់ពិសោធន៍ជាមួយវិធីផ្សេងៗ ក្នុងការអនុវត្តន៍ព្រះ



www.budinst.gov.kh www.elibraryofcambodia.org

ធម៌នៅក្នុងបរិបទនៃអធិករណ៍ ដែលក្លាយទៅជាព្រឹត្តិការណ៍អាក្រក់យ៉ាងឆាប់រហ័ស និងដែលបង្កើតឲ្យមានអារម្មណ៍ដ៏ល្វីងជូរចត់ខ្លាំង ។ យើងឃើញថាព្រះធម៌ពុំមែនជាដំបងទិព្វ ដោះស្រាយបញ្ហាបានភ្លាមៗទេ ។ អ្នកសំរបសំរួលបច្ចុប្បន្នត្រូវតែធ្វើការពិសោធន៍ដូចជាព្រះពុទ្ធអង្គដែរ ។ អ្វីដែលព្រះធម៌ ផ្តល់ឲ្យដោយពិតៗ គឺចិត្តវិទ្យាផ្នែកស្មារតី ដែលអាចជួយយើងឲ្យគាស់រំលើងនូវហេតុបច្ច័យនៃអធិករណ៍ និងឲ្យចាត់វិធានការណ៍ជាក់ស្តែង ដើម្បីធ្វើការប្រែធាតុ ។ បញ្ជីគុណសម្បត្តិនៃអ្នកសំរុះសំរួលដ៏មានប្រសិទ្ធិភាពរបស់ព្រះភិក្ខុឧបាលិ ពុំមានអ្វីប្លែកនៅក្នុងបច្ចុប្បន្ន និងនៅពេលដែលព្រះភិក្ខុបានសំដែងក្នុងអត្ថបទនេះទេ ។

## ជំពូក ២ : ការសំរុះសំរួលរវាងរដ្ឋកោលិយៈ និងសក្យៈ

## ២.១ សេចក្តីផ្តើម

នៅក្នុងជំពូកនេះ យើងនឹងពិនិត្យមើលនូវឧបទ្ទវហេតុមួយដែលព្រះពុទ្ធអង្គទ្រង់ធ្វើអន្តរាគមន៍រវាងប្រទេសជិតខាងគ្នាពីរ កោលិយៈ និងសក្យៈ ដែលហៀបតែនឹងផ្តើមសង្គ្រាមទៅហើយ ។ យើងនឹងសាកល្បងរាវរកធាតុទាំងឡាយរបស់ព្រះពុទ្ធអង្គ ដែលពាក់ព័ន្ធចំពោះអ្នកសំរុះសំរួលបច្ចុប្បន្ននេះ ។

## ២.២ ស្ថានការណ៍

ពួកសក្យៈ និងកោលិយៈ រស់នៅសងខាងស្ទឹងរោហិណី ។ វាលស្រែស្ថិតនៅទាំងសងខាងជាប់នឹងស្ទឹង ហើយខាងក្រោយនោះគឺរាជធានីនៃរដ្ឋតូចៗទាំងពីរនេះគឺកបិលវត្ថុជារាជធានីរបស់ពួកសក្យៈ និងរាមគាមជារាជធានីរបស់ពួកកោលិយៈ ។ រាជវង្សនៃប្រទេសទាំងពីរនេះ តែងតែរៀបអាពាហ៍ពិពាហ៍ទៅវិញទៅមក ហើយសុទ្ធតែជាសាច់ញាតិនៃព្រះគោត្តមសក្យមុនី ដែលជាព្រះពុទ្ធអង្គ ។ យើងដឹងថា ពីដើមរៀងមកដល់មុនពេលមានអធិករណ៍ ប្រជាជននៃប្រទេសទាំងពីរមានកិច្ចសហប្រតិបត្តិការល្អប្រសើរ ព្រោះគេមានទំនប់រួមគ្នាមួយដែលគេទប់ និងប្រើប្រាស់ទឹកសំរាប់ស្រោចស្រប់ស្រែចំការទាំងសងខាងពុំមាននរណាទាមទារយកកម្មសិទ្ធិនៃស្ទឹងនេះទេ ។

ហេតុបច្ច័យនៃការមិនស្រួល ដែលកើតក្នុងរដ្ឋជាបងប្អូននេះ គឺការរាំងស្ងួតជាច្រើនអាទិត្យនៅពេលមុនច្រូតកាត់ ។ ទឹកស្ទឹងរោហិណីនៅសល់តិចតួច ហើយប្រជាជនមិនច្បាស់ថា អាចនឹងមានភ្លៀងទៀត ឬពុំមានទេ ។ ពុំមានបញ្ហាក់ពីការខ្វាចឡំភ្លូទេ ប៉ុន្តែគេមានការព្រួយបារម្ភចំពោះសមាមាត្រនៃផលានុផលដែលអាចប្រមូលបាន ប្រសិនបើការរាំងស្ងួតនៅតែបន្ត ។

## ២.៣ ការឱ្យយោបល់

កសិករម្នាក់ ឬប្រធានក្រុមម្នាក់នៅក្នុងចំការជាជនជាតិកោលិយៈឲ្យយោបល់ថា ដោយទឹកពុំមានគ្រប់គ្រាន់សំរាប់ធ្វើឲ្យភោគផលនៃស្រែចំការទាំងសងខាងស្ទឹងចេញផ្លែផ្កាបាន គេគួរតែបង្វែរទឹកទាំងអស់ទៅដែនដីរបស់ពួកកោលិយៈ ។ អត្ថបទពុំបានបញ្ជាក់ពីការចែកចាយភោគផលទៅឲ្យពួកសក្យៈទេ ប៉ុន្តែយើងអាចស្មានថា ប្រហែលជាគេព្រមព្រៀងចែកគ្នាពាក់កណ្តាលម្នាក់ ។ ពួកពលករសក្យៈ ដែលមានការបារម្ភចំពោះភោគផលស្ងួចស្ដើងនៃការច្រូតកាត់ មានការសង្ស័យក្រែងពួកកោលិយៈរៀបចំប្រើប្រាស់ទឹកដោយផ្តាច់មុខ ។ គេបានសំដែងនូវការភ័យ


www.budinst.gov.kh www.elibraryofcambodia.org



ទំនាស់រវាងប្រជាជនរដ្ឋកោលិយៈ និងរដ្ឋសក្យៈ លើការប្រើប្រាស់ទឹក

www.budinst.gov.kh www.elibraryofcambodia.org

ខ្លាចនេះយ៉ាងច្បាស់ណាស់ ។

«នៅពេលណាលោកអ្នកបានភោគផលដាក់ក្នុងជង្រុករបស់លោកអ្នកហើយ យើងខ្ញុំប្រហែលជាពុំមានសេចក្តីក្លាហាននឹងយកមាសមាន់ពណ៌លឿងព្រឿងៗ ត្បូងមានតំលៃ និងលុយកាក់ជាមួយនឹងកញ្ជើឬបាវ កាន់ក្នុងដៃទៅដើររេរាមុខផ្ទះរបស់លោកអ្នកទេ ។ ដំណាំរបស់យើងខ្ញុំនឹងផុះដាលរីកចំរើនដោយការស្រោចទឹក ។ សូមលោកអ្នកផ្តល់ទឹកឲ្យយើងខ្ញុំផង» ។

បានសេចក្តីថាផែនការនឹងបណ្តាលឲ្យមានការពឹងផ្អែកទៅលើរដ្ឋកោលិយៈ ហើយពួកសក្យៈនឹងត្រូវយកទ្រព្យសម្បត្តិរបស់ខ្លួនទៅដូរយកស្រូវអង្ករនិងត្រូវក្លាយខ្លួនទៅជាអ្នកសុំឈ្នួលគេ ។ ពាក្យថា «ដើររេរានៅមុខផ្ទះ»បញ្ជាក់ថា មានការបាត់បង់នូវការគោរពខ្លួនឯង ដែលខ្លួនធ្លាប់មាន ។

## ២.៤ អធិករណ៍ឡើងរឹតតែខ្លាំង

នៅក្នុងពេលនេះបញ្ហាមិនជាពិបាកណាស់ណាទេ ដោយមានវិធីសំរាប់ភាគីទាំងសងខាងដោះស្រាយបញ្ហារួមគ្នា ដែលប្រហែលជាអាចរកដំណោះស្រាយ ដែលយល់ព្រមទាំងសងខាងបាន ។ ខ្លឹមសារនៃការព្រមព្រៀងអាចផ្តល់អាទិភាពចំពោះស្រែ ដែលផ្តល់ផលខ្ពស់ជាងគេ ដោយមានលក្ខខ័ណ្ឌថា ភោគផលនឹងត្រូវបែងចែកស្មើគ្នា ។ តាមពិតជាជាងការពិភាក្សារកវិធីផ្សេងៗដទៃទៀត ពួកគេខ្លះជជែកតាំទ្រ និងខ្លះតវ៉ាប្រឆាំងចំពោះសំណើរបស់ពួកកោលិយៈទៅវិញ ។

ពេលនោះមានភាពទ័លច្រកៈ

«យើងមិនព្រមទេ.....យើងក៏មិនព្រមដែរ»

ភាគីមួយគិតថា ភាគីមួយទៀតចង់គេងប្រវ័ញ្ចលើខ្លួន ហើយបានស្រែកខ្លាំងៗ ។ សេចក្តីរំជួលចិត្តបានចាប់ផ្តើមឡើងដល់កំរិតខ្ពស់ ។ កសិករម្នាក់បានក្រោយឈរឡើង ហើយទះកំភ្លៀងកសិករម្នាក់ទៀត ហើយម្នាក់នេះក៏ទះអ្នកទីបីជាបន្ត ។ ដោយសារគ្មានទីកធ្វើឲ្យពួកគេបែកបាក់គ្នា កសិករទាំងឡាយបានផ្តើមវាយតប់គ្នាក្នុងស្រែជាប់នឹងមាត់ស្ទឹងនោះ ។

ភាគីទាំងសងខាងបានស្រែកជេរគ្នាទៅវិញទៅមក ។ រួចមកកសិករកោលិយៈម្នាក់បានបញ្ជាឲ្យមិត្តរបស់គេស្ងាត់ ហើយស្រែកជេរយ៉ាងខ្លាំងដល់ពួកសក្យៈ ។

ការជេរប្រទេចគ្នាមានគោលបំណងនឹងធ្វើឲ្យគូភាគីមានអារម្មណ៍អាក្រក់ចំពោះខ្លួនឯង ។ ការធ្វើឲ្យអ្នកដទៃខ្សោយ គឺធ្វើឲ្យគេងាយយល់ថា យើងមានសន្តិសុខ និងតំលៃជាងគេ ក្នុងការប្រៀបធៀបគ្នា ។ ដោយសារជំលោះនេះជាជំលោះរវាងសហគមន៍ ពោលគឺពុំមែនជាជំលោះរវាងបុគ្គល ដូចនេះគឺជារូបភាពផ្ទាល់របស់សហគមន៍ ពោលគឺព្រះរាជវង្សានុវង្សរបស់គេ ដែលត្រូវគេវាយប្រហារ ។

«ចូរអ្នកចេញទៅជាមួយអ្នកស្រុកកបិលវត្ថុជាមនុស្សដែលស្រឡាញ់ផ្តៅព្រៃ ហើយដោយហេតុនេះជាមនុស្សដូចសត្វពាឡព្រឹក រស់នៅជាមួយប្អូនស្រីរបស់ខ្លួនបង្កើត ។ តើមានប្រយោជន៍អ្វីនឹងយកដំរី និងសេះ ខែល និងលំពែងរបស់គេមកប្រឆាំងយើង?» ។

ពួកកសិករសក្យៈតបថា៖ «នែពួកអ្នកឃ្លង់ពីទុគ៌ត ចូរចេញទៅជាមួយកូនអ្នកឯង និងមិត្តភក្តិទ័លក្រ និងទុរ្ជនទុរាររបស់អ្នកឯង ដែលរស់នៅក្នុងព្រាង់ដើមកោលៈ (ពុទ្រា) ដូចសត្វពាឡព្រឹកសាហាវ ។ តើអ្នកមានប្រយោជន៍អ្វីនឹងយកដំរី និងសេះ ខែល និងលំពែងរបស់គេមកប្រឆាំងនឹងយើង?» ។

នៅទីនេះការជេរប្រទេចគ្នាឡើងដល់កំរិត ដែល



www.budinst.gov.kh www.elibraryofcambodia.org

ពុំមែនជាមនុស្ស គេហៅគ្នាទៅវិញទៅមកថា ឆ្កែព្រៃ និងរុក្ខបិសាច ។ បើអធិករណ៍នេះក្លាយទៅជាសង្គ្រាម អាកប្បកិរិយាបែបនេះអាចនឹងធ្វើឲ្យប្រជាជន ដែលរួមរស់នៅជាមួយគ្នារាប់ជំនាន់មកហើយនោះសំលាប់គ្នាទៅវិញទៅមក ។

## ២.៥ រាជវង្សទាំងឡាយបានចូលរួម

ព្រះអាទិត្យចូលអស្តង្គត ហើយក្នុងពេលព្រលប់កសិករបានដើរត្រឡប់ទៅកាន់រាជធានីរៀងៗខ្លួន ដោយនិយាយគ្នាទាំងកំហឹងចំពោះការជេរប្រមាថពីប្រជាជននៅត្រើយម្ខាង ដែលកំពុងស្ថិតជំនៅក្នុងត្រចៀករបស់គេនៅឡើយ ។

របាយការណ៍អំពីរឿងនេះបានឡើងទៅដល់មហាក្សត្រ និងទីប្រឹក្សាព្រះអង្គ ដែលនាំឲ្យទ្រង់ចាប់អារម្មណ៍ចំពោះការជេរប្រមាថដល់កិត្តិនាមរបស់ព្រះអង្គ ។ ពុំមាននរណាអាចបដិសេធនូវការជេរប្រមាថនេះទេ ព្រោះមានរឿងនិទានបែបនេះពីអតីតកាលមក ។

អត្ថបទបានថែងអំពីការពិភាក្សានៅក្នុងរាជវាំងនៃរាជធានីទាំងពីរ ដូចខាងក្រោមនេះ៖

រួចពួកសក្យៈពោលថា «យើងនឹងបង្ហាញថាតើអ្នកដែលរស់នៅជាមួយប្អូនស្រីខ្លួនមានកំលាំងខ្លាំងនិងពូកែយ៉ាងណា?» ហើយគេក៏រត់សំរុកចេញទៅដើម្បីប្រឈ្លោះគ្នា ។

ហើយពួកកោលិយៈឆ្លើយតប «យើងនឹងបង្ហាញថា តើអ្នកដែលរស់នៅក្នុងព្រៃដើមព្រុទ្រាមានកំលាំង និងពូកែយ៉ាងណា?» ហើយគេក៏រត់សំរុកចេញទៅដើម្បីវាយគ្នា ។

ភាគីម្ខាងៗមានបំណងចង់ឲ្យភាគីមួយទៀតគោរពខ្លួន ដោយការប្រើប្រាស់កំលាំង ។ ដោយពាក្យសំដីមិនអាចធ្វើឲ្យភាគីម្ខាងស្តាប់បាន និងមិនអាចសំរេចបាននូវការស្រម៉ើស្រមៃធ្វើឲ្យគេស្តាប់ខ្លួន នៅក្នុងវង្វង់គថភាពបាន គេនឹងស្រោចស្រង់«មុខមាត់» របស់គេតាមកំលាំងយោធា ។ បញ្ហាទឹកពុំមែនជាខ្លឹមសារនៃការពិភាក្សាគ្នាទេ បានសេចក្តីថា គេពុំបានលើកយកបញ្ហាទឹកមកដោះស្រាយក្នុងការសន្ទនារបស់គេទាល់តែសោះ ។ អ្នកដឹកនាំនៃរដ្ឋនិមួយៗបានរៀបចំសង្គ្រាមនេះ ពុំមែនដើម្បីអនុវត្ត ឬដើម្បីប្រឆាំងនឹងគោលនយោបាយទឹកទេ ប៉ុន្តែមកពីបញ្ហាជេរប្រមាថចំពោះរាជវង្សានុវង្ស ។

ពេលព្រលឹមស្រាងៗកងទ័ពទាំងពីររង្គប្រដាប់ដោយលំពែង និងដាវ តំរៀបដាក់លើខ្នងដំរី និងសេះបានធ្វើដំណើរឆ្ពោះទៅមាត់ស្ទឹងរោហិនី ។ សង្គ្រាមនឹងផ្ទុះឡើងនៅពេលអរុណរះ ។

## ២.៦ ព្រះសម្មាសម្ពុទ្ធទ្រង់សំរេចព្រះទ័យធ្វើអន្តរាគមន៍

ព្រះពុទ្ធអង្គទ្រង់គង់នៅក្រៅក្រុងកបិលវត្ថុ បានទទួលពត៌មានអំពីស្ថានការណ៍នេះ នៅពេលព្រះអង្គគង់សមាធិ ។ ក្នុងការសំរេចព្រះទ័យធ្វើអន្តរាគមន៍ព្រះពុទ្ធអង្គទ្រង់ពិចារណានូវសំនួរពីរ៖

* តើរឿងរ៉ាវនឹងទៅជាយ៉ាងណា បើតថាគតមិនទៅរកគេ?

* តើតាមការពិតតថាគតអាចជួយគេបានទេ?

ក្នុងចំណោមកត្តា ដែលនាំឲ្យព្រះពុទ្ធអង្គពិចារណា ហើយធ្វើសេចក្តីសន្និដ្ឋានតើការពិតព្រះអង្គអាចជួយគេបាន ព្រោះព្រះអង្គមានទំនាក់ទំនងល្អជាមួយប្រជាជនទាំងពីរភាគី-ព្រះមាតាព្រះអង្គជាវង្សត្រកូលកោលិយៈ ហើយព្រះបិតាជារាជានៃនគរសក្យៈ ហើយព្រះអង្គមានមេត្រីភាពផ្ទាល់ជាមួយស្តេចបសេនទិនៃនគរកោសល ដែលជានគរត្រួតត្រាលើនគរកោ



www.budinst.gov.kh www.elibraryofcambodia.org



មហាក្សត្រ ឧបរាជ នាម៉ឺន មេទ័ព.....មានការខ្មាសអៀនចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធអង្គ

www.budinst.gov.kh www.elibraryofcambodia.org

លិយៈ និងសក្យៈ ។

«បើតថាគតបណ្តែតបណ្តោយមិនទៅរកគេ មនុស្សទាំងពីរភាគីនឹងសំលាប់គ្នាទៅវិញទៅមក ។ករណីកិច្ចរបស់តថាគត គឺត្រូវតែទៅរកគេ ។ បើតថាគតអញ្ជើញនៅទីនេះ តើបញ្ហាត្រូវចប់ទេ? ។ តថាគតត្រូវទៅទីនោះ ដើម្បីរំងាប់អធិករណ៍នេះ...»

## ២.៧ «យើងមិនអាចវាយប្រយុទ្ធគ្នាទេ...»

ព្រះពុទ្ធអង្គទ្រង់យាងទៅកាន់សមរភូមិ ហើយទ្រង់យាងទៅនៅចន្លោះកងទ័ពទាំងពីរ ។ ចោមរោមគ្រប់ទិសទីដោយមនុស្សមានអាវុធ ព្រះពុទ្ធអង្គទ្រង់ពុំមានអាវុធទេ ប៉ុន្តែព្រះអង្គទ្រង់មានឥទ្ធិពលដ៏ពិត។ ។

នៅពេលដែលឃើញព្រះពុទ្ធអង្គ ពួកសក្យៈបែរជាស្រងាកចិត្ត និងខ្មាសអៀន ។ «ព្រះបរមគ្រូជាព្រះញាតិដ៏ប្រសើររបស់យើងទ្រង់យាងមកហើយ ។ តើព្រះអង្គបានជ្រាបហេតុបច្ច័យពិតសំរាប់ការវាយប្រហារគ្នានេះទេ?» ។

ដូចជាកូនក្មេងដែលដេញទាន់នៅក្នុងពេលកំពុងប្រព្រឹត្តអំពើមិនគប្បីអ្វីមួយ វត្តមានរបស់ព្រះពុទ្ធអង្គបានធ្វើឲ្យខកខានទូវដំណើរការ ដែលកំពុងប្រព្រឹត្តទៅ ហើយបាននាំមកនូវការផ្លាស់ប្តូរចិត្តគំនិតខ្លះ។ ។

«ឥឡូវព្រះបរមគ្រូបានយាងមកហើយ ពួកយើងមិនអាចលើកអាវុធប្រហារគ្នាទេ» ហើយគេក៏ទំលាក់អាវុធរបស់គេចុះ ។

ពួកកោលិយៈក៏បានប្រព្រឹត្តដូចគ្នាបេះបិទ «បូរណភាពនៃព្រះបញ្ញាញាណរបស់ព្រះសម្មាសម្ពុទ្ធបានធ្វើឲ្យអ្នកដឹកនាំដែលមានគំនិតខូច និងល្ងិល្ងើ ទៅជាមានគំនិតសង្គ្រោះទៅវិញ ។ គេលែងជៀលហៅពួកកោលិយៈថា ជាសត្វ តែជាមនុស្សធម្មតាវិញ ។

## ២.៨ ការរកហេតុផល

ដោយបានទិចន្តយាងទៅស្ថិតនៅចំកណ្តាលសមរភូមិ និងដោយមានពួកយោធាបានឡោមព័ទ្ធជុំវិញ ព្រះពុទ្ធអង្គទ្រង់ក៏បានសាកសួរមហាក្សត្រសក្យៈអំពីហេតុបច្ច័យនៃអធិករណ៍ នេះគឺជារឿងកំប្លែងដែលជាខ្លឹមសារនៃការសន្ទនានេះ៖

ព្រះពុទ្ធអង្គទ្រង់ពោលទៅកាន់ញាតិរបស់ព្រះអង្គ៖ «ម្នាលមហាក្សត្រ តើអ្វីដែលនាំឲ្យមានជំលោះគ្នានេះ?»

«បពិត្រព្រះអង្គ ទូលព្រះបង្គំយើងខ្ញុំមិនដឹងទេ ព្រះបរមគ្រូ»

«ដូច្នេះ តើអ្នកណា ដែលអាចដឹង?»

«លោកមេបញ្ជាការកងទ័ពប្រហែលជាអ្នកដឹង»

លោកអគ្គមេបញ្ជាការកងទ័ពពោលថា៖ «លោកឧបរាជប្រហែលជាអ្នកដឹង» ។ បន្ទាប់មកព្រះពុទ្ធអង្គទ្រង់សាកសួរពីម្នាក់ទៅម្នាក់ រហូតដល់ពួកទាសពលករក្រោយគេបំផុត ។ ពួកទាសពលករឆ្លើយត្រឹមត្រូវតាមរឿងពិតខ្លះ ប៉ុន្តែក៏បានទុកមុខថ្វាយមហាក្សត្រដែរថា៖ «បពិត្រព្រះដ៏មានព្រះភាគ ជំលោះគឺមកពីបញ្ហាទឹក» ។

សង្គ្រាម ដែលអាចគ្រោងនេះមិនអាចដោះស្រាយទៅតាមដំណើររឿងទេ ហើយក្សត្រសក្យៈមានការខ្មាសអៀនច្រើន ។ មន្ត្រីព្រះអង្គពុំបានខិតខំសាកល្បងពន្យល់ស្ថានការណ៍ថា មកពីការរំលងស្លុតទឹកទេ គេបានដឹងថា បុព្វហេតុពិត គឺបណ្តាលមកពីការបាត់បង់កិត្តិយស ។ ប៉ុន្តែពួកទាសពលករទាំងនោះ បែរជាពោលថា មកពីបញ្ហាទឹក ។ តាមពិតនេះជាចំនុច



www.budinst.gov.kh www.elibraryofcambodia.org

ផ្តើមនៃអធិករណ៍ គេពុំមានបំណងធ្វើឲ្យចៅហ្វាយនាយរបស់គេអៀនខ្មាស ដោយបកអាក្រាតពីការជេរប្រទេចគ្នាទេ ។ គេបានជួយសង្គ្រោះមុខមាត់ ប៉ុន្តែហេតុបច្ច័យពិតនៃការរៀបចំសង្គ្រាម ត្រូវបានលាក់បាំង ។

## ២.៩ ការប្រឹងប្រែងរកតំលៃ

ព្រះពុទ្ធអង្គទ្រង់បានបង្ហាញ ចំពោះព្រះមហាក្សត្រនូវផលវិបាកពាក់ព័ន្ធនឹងអំពើរបស់ព្រះរាជា ហើយព្រះអង្គបានប្រឹងប្រែងលើកទឹកចិត្តមហាក្សត្រឲ្យមើលឃើញនូវអ្វី ដែលមានសារៈសំខាន់សំរាប់គេ ។

ព្រះពុទ្ធអង្គទ្រង់ពោលទៅកាន់ព្រះមហាក្សត្រសក្យៈថា៖

«បពិត្រមហារាជ តើទឹកនេះថ្លៃប៉ុន្មាន?»

«បពិត្រព្រះដ៏មានព្រះភាគ ទឹកនេះមានតំលៃតិចតួចណាស់»

«តើខត្តិយៈ (អ្នកចំបាំង) មហារាជមានតំលៃប៉ុន្មានដែរ មហារាជ?»

«បពិត្រព្រះដ៏មានព្រះភាគ ខត្តិយៈមិនអាចកាត់ថ្លៃបានទេ»

«តើជាការសមស្របទេ ព្រោះតែទឹកបន្តិចនេះមហារាជអាចនឹងកំទេចខត្តិយៈ ដែលមិនអាចកាត់ថ្លៃបាន?»

ព្រះរាជាមិនអាចឆ្លើយតបបានទេ ប៉ុន្តែមុខឡើងក្រហម ព្រោះការអៀនខ្មាស ។

ព្រះពុទ្ធអង្គទ្រង់មានបន្ទូលទៅកាន់មហាក្សត្រទាំងពីរថា៖

«បពិត្រមហារាជ ហេតុដូចម្តេចបានជាព្រះអង្គប្រព្រឹត្តបែបនេះ? បើតថាគតពុំមានវត្តមានថ្ងៃនេះទេ ព្រះអង្គនឹងមានស្ទឹងមួយ ប៉ុន្តែគឺជាស្ទឹងឈាម ។ ព្រះអង្គបានប្រព្រឹត្តនូវអំពើ ដែលមិនសមទាល់តែសោះ ។ ព្រះអង្គរស់នៅក្នុងអរិយភាព ដោយបណ្តោយខ្លួនក្នុងទោសៈទាំង៥ប្រភេទ ។ ចូរយើងរស់នៅដោយរីករាយ ដោយប្រាសចាកនូវទោសៈក្នុងចំណោមអ្នកដែលមានទោសៈ ។ ក្នុងចំណោមអ្នកដែលមានទោសៈ ចូរយើងរស់នៅដោយប្រាសចាកនូវទោសៈ» ។

## ២.១០ ដើមចមនៃអធិករណ៍

ក្នុងការសន្ទនាជាមួយព្រះពុទ្ធ គ្មានមហាក្សត្រអង្គណាបាននិយាយថា មោទនភាពខូចខាត គឺជាហេតុពិតនៃការផិតធ្វើសង្គ្រាមនោះទេ ។ តាមខ្លឹមសារនៃធម្មទេសនា អវិជ្ជាគឺជាលក្ខខ័ណ្ឌដែលនាំឲ្យអារម្មណ៍បែបនោះមានដំណើរឡើង ។ ដូចដែលយើងនឹងឃើញនៅក្នុងភាគបន្ទាប់នៃសៀវភៅបែបនេះអកុសលមូល-លោភៈ ទោសៈ និងមោហៈ បានលេចចេញពីនេះ ។ ព្រះពុទ្ធអង្គទ្រង់បានលើកឡើងនូវហេតុតាមចិត្តវិទ្យានៃអធិករណ៍ ដោយការប្រៀបធៀប៖

«ជាការពិតណាស់នៅក្នុងជំលោះនេះពុំមាននរណាសោមនស្សទេ ប៉ុន្តែដោយសារការប្រឆាំងគ្នារវាងរុក្ខទេវតា និងគោខ្មៅមួយនាំឲ្យមានស្ថានការណ៍ដូចបច្ចុប្បន្ននេះ» ។

ព្រះពុទ្ធអង្គទ្រង់បានប្រាប់មហាក្សត្រទាំងឡាយអំពីកំណើតគន្ធូន ។ នៅជិតក្រុងពារាណសី មានភូមិជាងឈើមួយ ហើយជិតភូមិនោះមានព្រៃមួយ ។ ជាងឈើក្នុងភូមិនោះ តែងចេញទៅព្រៃដើម្បីរកឈើធ្វើកង់ និងរទេះ ។ ថ្ងៃមួយមានខ្យល់ឃើងខ្លាំងគោខ្មៅមួយបានដេកក្រោមដើមឈើមួយ នៅពេលខ្ទួនរកអាហារ ។ ខ្យល់បានបក់ឃើងខ្លាំងធ្វើឲ្យមែក



www.budinst.gov.kh www.elibraryofcambodia.org



ដំណើររឿងនិទានអំពីសត្វតោ និងរុក្ខទេវតា

www.budinst.gov.kh www.elibraryofcambodia.org

ឈើមួយបាក់ ហើយធ្លាក់មកលើគោ ដែលធ្វើឲ្យវាភ្ញាក់ ។ គោគិតថា ប្រហែលជាសត្វផ្សេងទៀតមកប្រហារវា វាក៏ងើបឡើងក្រឡេកមើលជុំវិញ ។ ដោយពុំឃើញមានសត្វណាមួយ គោសន្និដ្ឋានថា រុក្ខទេវតាបានកាច់មែកឈើដោយចេតនា ។ គិតដូច្នោះ គោក៏ខឹង វាយប្រហារឈើ ហើយស្រែក៖ «ខ្ញុំមិនដែលស៊ីស្លឹកឯង ឬកាច់បំបាក់មែករបស់ឯងទេ ។ ឯងរួមគំនិតជាមួយសត្វដទៃ នៅក្នុងដើមឈើ ។ តើខ្ញុំធ្វើអ្វីខុស? ប៉ុន្តែខ្ញុំនឹងបង្ហាញឯង ខ្ញុំនឹងដកឯងចេញពីក្នុងដី ឫស និងមែកឯង ខ្ញុំនឹងចិញ្ច្រាំឲ្យខ្ទេច» ។ ពោលរួចហើយ វាក៏ដើរចេញទៅឆ្ងាយបន្តិច វាក៏ជួបនឹងជាងឈើម្នាក់ និងអ្នកជំនួយការពីរនាក់ ។ រីករាយនឹងបានជួបគោដែលចេះនិយាយ ជាងឈើបានចាប់អារម្មណ៍ជាខ្លាំងចំពោះការផ្តល់ពត៌មានរបស់គោអំពីដើមឈើដ៏ប្រសើរបំផុតសំរាប់ធ្វើកង់ ។ ដោយគិតថា វាអាចបញ្ចុះបញ្ចូលឲ្យជាងឈើកាប់រំលំដើមពង្រ គោនោះក៏នាំអ្នកទាំងនោះទៅដល់ដើមឈើនោះ ហើយពោលថា៖ «នេះជាដើមឈើ ដែលមានឈ្មោះថា ពង្រគឺជាឈើម្យ៉ាងប្រសើរបំផុតសំរាប់ធ្វើកង់» ។ គោរីករាយខ្លាំងណាស់ នៅពេលជាងឈើកាប់រំលំដើមឈើនោះ ។

រុក្ខទេវតាមិនសប្បាយចិត្តទាល់តែសោះ៖ «ខ្ញុំមិនដែលធ្វើអ្វីអាក្រក់ចំពោះគោនេះសោះ ។ វាខឹងដោយគ្មានហេតុផល បង្ករឿង ហើយឥឡូវវាចាប់ផ្តើមបំផ្លាញផ្ទះរបស់ខ្ញុំ ។ ហើយខ្ញុំក៏នឹងត្រូវខ្ទេចខ្ទីដែរ ។ ខ្ញុំត្រូវតែបំផ្លាញវាមុនពេលវាបំផ្លាញខ្ញុំ» ។ រុក្ខទេវតាក៏បានកាឡាខ្លួនជាម្នើរព្រៃ ហើយដើរទៅជួបជាងឈើ ។ ក្រោយពីសាកសួរអំពីហេតុផល ដែលចង់បានដើមឈើ រុក្ខទេវតាបានពោលថា៖

«ខ្ញុំប្រាប់អ្នកមុន បើអ្នកពន្ធះស្បែកពីកញ្ចឹងកគោខ្មៅ ហើយដាក់ព័ទ្ធជុំវិញរង្វង់កង់ខាងក្រៅ ដូចជាស្បែកស្រោបទទឹងប្រហែលបួនធ្នាប់ កង់នោះនឹងរឹងមាំ ហើយអ្នកនឹងចំណេញច្រើន» ។ ជាងឈើសើចហើយស្រែកថា៖ « ជាការពិតណាស់! ថ្ងៃនេះខ្ញុំមានលាភអស្ចារ្យ!» ។ រួចជាងឈើក៏សំលាប់គោកាប់រំលំដើមឈើ ហើយត្រឡប់ទៅវិញដើម្បីធ្វើកង់ ។

យើងអាចយល់រឿងនេះបានតាមក៏រិតផ្សេងៗគ្នា ។ នៅក៏រិតមួយ គឺជាមេរៀនអំពីឧបនិស្ស័យរបស់អធិករណ៍ ដែលបំរុងនឹងរាលដាលរហូតដល់ទប់លែងឈ្នះ ប្រសិនបើគេពុំបានដោះស្រាយបានដោយព្រះធម៌ ។ ដោយខិតខំបំផ្លាញគ្នាទៅវិញទៅមក រុក្ខទេវតា និងគោខ្មៅ ត្រូវបញ្ចប់បញ្ហា ដោយត្រូវគេបំផ្លាញទាំងពីរ ដូចករណីខាងលើនេះ ។ ការពារខ្លួនឯង ហើយវាយប្រហារអ្នកដទៃ នឹងធ្វើឲ្យខ្លួនឯងងាយរងគ្រោះ ។

នៅក៏រិតមួយទៀត គឺជាពាក្យបញ្ជិតបញ្ជៀងចំពោះរឿងព្រេងអំពីរាជវង្សានុវង្ស ។ មានជំនឿថាពួកកោលិយៈមានប្រភពកំណើតពីរុក្ខទេវតា ហើយព្រះពុទ្ធអង្គទ្រង់ពោលថា ជំលោះនេះ «បានបន្តរហូត» មកដល់សព្វថ្ងៃនេះ ។ សារៈសំខាន់គឺថា ជំលោះនេះ អាចគ្រាន់តែនាំមកនូវទុក្ខវេទនាដល់ប្រជារាស្ត្រដែលពាក់ព័ន្ធតែប៉ុណ្ណោះ ។ អ្នកដែលបានទទួលកំរៃមានតែតួអង្គពីរ ដែលត្រូវបណ្តេញដោយមោហៈ តំណាងដោយរាជវង្សត្រកូលពីរ ដែលជាគម្រូនៃការជេរប្រទេច ។ រឿងនេះពុំមែនមានវត្ថុមានពិតទេ ប៉ុន្តែជាការបំភាន់គំនិតរបស់យើង ដែលយើងមានជំនឿតគ្នាមកពីជំនាន់មួយទៅជំនាន់មួយ ។

គួរឲ្យចាប់អារម្មណ៍ដែរថា ថ្វីបើមោហៈ គឺជាចំនុចស្នូលនៃការបកស្រាយស្ថានការណ៍របស់ព្រះសម្មាសម្ពុទ្ធផ្ទាល់ក៏ដោយ ក៏ព្រះអង្គទ្រង់មិនលើកឡើងដែរ លុះដល់ទីបញ្ចប់ទើបទ្រង់លើកឡើង ។ ព្រះពុទ្ធអង្គទ្រង់ទតមើលតែបញ្ហាសីលធម៌ និងការនិយម



www.budinst.gov.kh www.elibraryofcambodia.org

(សំអាងលើលទ្ធផល ) ដែលជាការបារម្ភភ្លាមៗមុន គេបង្អស់ចំពោះភាគីជំលោះ ហើយតាមពិត គឺជាការ ដែលស៊ីជ្រៅជាងនេះទៅទៀត ។

ប្រធានបទដែលថា ពុំមានការពេញចិត្តនៅក្នុងជំលោះ នឹងត្រូវលើកឡើងនៅក្នុងរឿងពីរក្រោយទៀត ។ ក្នុងរឿងទី១ថា បើសួរកឲ្យឃើញនូវចំនុចខ្សោយរបស់ភាគីនីមួយៗ វាអាចធ្វើទុក្ខធ្វើទោសបាន ដោយមិនគិតពីភាពខ្សោយ ឬភាពខ្លាំងទេ ។ រឿងទី២ពាក់ព័ន្ធនឹងពួកវជ្ជិក្នុងមហាបរិនិព្វានសូត្រ ដែលថា ឯកភាពគឺជាគ្រឹះពិតនៃកំលាំង ។

«ក្នុងករណីដែលគេបានរួមរស់នៅជាមួយគ្នាដោយឯកភាព ពុំមាននរណាអាចរកច្រកសំរាប់វាយប្រហារបានទេ ប៉ុន្តែនៅពេលគេឈ្លោះគ្នាទៅវិញទៅមក អ្នកប្រមាញ់ម្នាក់បាននាំមកនូវវិនាសកម្ម ហើយចាកចោលទៅ ។ ជាការពិតណាស់ នៅក្នុងជំលោះពុំដែលមានការពេញចិត្តទេ» ។

អ្នកប្រមាញ់ម្នាក់នោះប្រហែលជាមារ ។ ភាពពុំមានឯកភាពនឹងនាំមកនូវគ្រោះអន្តរាយ ។

ដំបូន្មានមួយទៀត ដែលតែងតែបញ្ជាក់តាមមធ្យោបាយច្រើនយ៉ាង គឺថែងអំពីសារៈសំខាន់នៃសតិៈ

មិនត្រូវឲ្យមានមោហសម្ព័ន្ធបែបនេះបន្តពីមួយទៅមួយទេ ។ នៅទីនេះព្រះពុទ្ធអង្គទ្រង់សំដៅជាពិសេសរឿង ដែលកោតៈធ្វើដំណើររកសាយនៅចំណោមកសិករ និងរាជវង្សានុវង្សនៃភាគីម្ខាងៗ ។ ទេសភាពដែលធ្វើឲ្យសើច ដែលព្រះពុទ្ធអង្គទ្រង់សាកសួរមហាក្សត្រ អគ្គមេបញ្ជាការទ័ព ឧត្តមសេនីយ៍ និងទីប្រឹក្សាមានទំនាក់ទំនងទៅនឹងជាតកមួយទៀត និទានពីទន្សាយព្រៃមួយ ដែលភ្ញាក់ផ្អើលនឹងសំលេងផ្លែត្នោតជ្រុះ បានធ្វើឲ្យសត្វដទៃទៀតភ័យឆោឡោ ដោយស្មានតែផែនដីក្រឡាប់ ។ បើយើងពុំមានសតិ យើងពុំអាចគ្រប់គ្រងស្ថានការណ៍បានឡើយ ។

## ២.១១ មេរៀនដែលត្រូវរៀន

មានទិដ្ឋភាពខ្លះនៃអន្តរាគមន៍របស់ព្រះពុទ្ធអង្គ ដែលមានការពាក់ព័ន្ធទៅនឹងកិច្ចប្រតិបត្តិរបស់អ្នកសំរុះសំរួលជាភិក្ខុសង្ឃសព្វថ្ងៃ ។

### ចំលើយតបឲ្យទាន់ពេល

ព្រះពុទ្ធអង្គទ្រង់ជ្រាបពីអធិករណ៍ ក្នុងខណៈដែលធ្ងន់ធ្ងរ ពោលគឺពេលដែលអំពើហិង្សាហៀបតែរីកសាយឡើង ។ ចំលើយតបទាន់ពេលវេលារបស់ព្រះពុទ្ធអង្គ អាចបំបែរឧប្បត្តិហេតុ ដែលអាចធ្វើឲ្យទំនាក់ទំនងសក្យៈ - កោលិយៈ វិនាសអន្តរាយរាប់ឆ្នាំទៅមុខ ។ អធិករណ៍មានផ្លូវរីករាលដាលយ៉ាងលឿន ដែលមិនងាយទប់បាន ហើយចាំបាច់ត្រូវតែលូកដៃចូល ដោយគ្រាន់តែចូលទាក់ទងជាមួយភាគីទាំងនោះឲ្យបានលឿន ដែលអាចធ្វើបាន ។ ការសំរេចព្រះទ័យរបស់ព្រះពុទ្ធអង្គដើម្បីសំរុះសំរួល ព្រោះតែទ្រង់ទតឃើញនូវភាពចាំបាច់ជាបន្ទាន់នៃព្រឹត្តិការណ៍ ។

### បញ្ញាញាណ

បញ្ញាញាណរបស់ព្រះពុទ្ធអង្គមានអានុភាពយ៉ាងខ្លាំងទៅលើភាគីជំលោះ ។ ថ្វីបើមហាក្សត្រមានឥទ្ធិពលយោធាដ៏អស្ចារ្យក៏ដោយ ក៏ព្រះពុទ្ធអង្គមានឥទ្ធិពលខ្លាំងជាងយ៉ាងឆ្ងាស់ ប៉ុន្តែដោយរបៀបប្លែកពីគ្នា ។ ប្រៀបធៀបទៅនឹងព្រះពុទ្ធអង្គ មហាក្សត្រទាំងពីរអង្គទ្រង់បានយល់ភាពគ្មានតំលៃនូវអ្វី ដែលទ្រង់បំរុងនឹងធ្វើ ។ ដំណាក់ការរីកឡើងនៃអធិករណ៍ត្រូវបានបញ្ឈប់ដោយភាគីជំលោះភ្ញាក់រលឹកភ្លាមៗ អំពីការប្រព្រឹត្តរបស់ខ្លួន ដោយគេមានអារម្មណ៍ថា ព្រះពុទ្ធអង្គទ្រង់ទតឃើញរឿងហេតុនោះហើយ ។ ភិក្ខុសង្ឃបាននិទានឡើងវិញនូវបទពិសោធន៍ប្រហាក់ប្រហែល ដែលអ្នកស្រុកមិនអាចជជែក បង្ហាញនូវមតិ



www.budinst.gov.kh www.elibraryofcambodia.org

សំអាងផ្សេងៗ នៅចំពោះវត្តមានរបស់លោក ។ នេះជាឱកាសមួយផ្តល់ឲ្យមានការចាប់ផ្តើមនូវដំណើរការសន្ទនាគ្នា ។

## អព្យាក្រឹត្យភាព

ថ្វីបើព្រះអង្គចេញពីសក្យៈត្រកូល ក៏ពុំមាននរណាសង្ស័យថា ព្រះពុទ្ធអង្គទ្រង់ពុំមានអព្យាក្រឹត្យភាពក្នុងជំលោះនោះដែរ ។ នេះប្រហែលមកពីព្រះអង្គត្រូវបានគេទទួលស្គាល់ថា ព្រះអង្គទ្រង់គង់ «នៅលើ» រឿងរ៉ាវកំប៉ិចកំប៉ុក ដែលបង្កជំលោះ ។ សេចក្តីករុណាដ៏ឥតសៅហ្មង គឺជាគុណសម្បត្តិយ៉ាងជាក់ស្តែងសំរាប់អ្នកសំរុះសំរួលប្រតិបត្តិ ។ ហេតុដែលជំរុញព្រះពុទ្ធអង្គឲ្យទ្រង់រួមចំណែកក្នុងអធិករណ៍ គឺសេចក្តីករុណាចំពោះគ្រប់អ្នកដែលរងទុក្ខ ពុំមែនគ្រាន់តែចំពោះសហគមន៍ជាក់លាក់ណាមួយទេ ។

## អធិករណ៍ប្រើសំរាប់បង្រៀនព្រះធម៌

ព្រះពុទ្ធអង្គទ្រង់ប្រើប្រាស់អធិករណ៍សំរាប់បង្រៀនព្រះធម៌ ប៉ុន្តែក្នុងបែបបទដ៏ប៉ិនប្រសប់ និងជាក់ស្តែង ដែលនាំព្រះរាជាឲ្យចេះចោទសួរអំពីហេតុជំរុញ និងតំលៃរបស់ព្រះអង្គ ។ដោយលើកយកបញ្ហាដែលអាចបណ្តាលឲ្យបាត់បង់កេរ្តិ៍ឈ្មោះ និងកិត្តិយសព្រះពុទ្ធអង្គទ្រង់អាចចង្អុលបង្ហាញអំពីភាពឥតប្រយោជន៍នៃជំលោះ ដោយពុំធ្វើឲ្យភាគីណាបាក់មុខឡើយ ។

ជាញឹកញយ ភាគីនៃជំលោះមិនសប្បាយចិត្តចំពោះបែបបទ ដែលរៀងហេតុទាំងឡាយកំពុងប្រព្រឹត្តទៅទេ ហើយមានបំណងនឹងរកមធ្យោបាយប្រសើរៗសំរាប់ទប់ស្កាត់អធិករណ៍ ។ ប៉ុន្តែថា ការប្រៀនប្រដៅត្រូវតែធ្វើដោយប៉ិនប្រសប់ ។ ក្នុងករណីនេះ ព្រះពុទ្ធអង្គទ្រង់បង្រៀនព្រះធម៌ ដោយការអនុវត្តន៍ព្រះធម៌នោះដោយជាក់ស្តែង ពុំមែនតាមរយៈការទេសនាព្រះធម៌នោះទេ ។

# សេចក្តីសន្និដ្ឋាន :

ព្រះពុទ្ធអង្គទ្រង់បង្រៀនថា ព្រះធម៌ជាមធ្យោបាយដ៏សមស្របសំរាប់បំបាត់ទុក្ខ ។ កាលណាគម្ពីរនិយាយអំពីទុក្ខ គម្ពីរនោះច្រើនតែនិយាយអំពីអធិករណ៍ ហើយជាការច្បាស់ណាស់ ដែលព្រះពុទ្ធអង្គក៏ទ្រង់យល់ថា ព្រះធម៌គឺជាចំលើយចំពោះអធិករណ៍ដែរ ។

ចំលើយតបរបស់ព្រះពុទ្ធអង្គ ចំពោះអធិករណ៍មានន័យច្បាស់ណាស់ ព្រះអង្គទ្រង់ជាអ្នកកសាងសន្តិភាពដោយផុសចេញពីសេចក្តីករុណា ទ្រង់ស្វែងរកហេតុបច្ច័យនៃអធិករណ៍ រួចធ្វើការពិសោធន៍តាមរបៀបផ្សេងៗ ដើម្បីផ្សះផ្សារភាគីជំលោះ ។

ដូចយើងបានឃើញហើយ ព្រះពុទ្ធអង្គទ្រង់បានជួបនឹងការលំបាក ។ អ្នកកសាងសន្តិភាពសព្វថ្ងៃក៏តែងជួបប្រទះនឹងស្ថានការណ៍ប្រហាក់ប្រហែលនឹងស្ថានការណ៍របស់ព្រះពុទ្ធអង្គដែរ ។ អធិករណ៍ច្រើនតែលំបាកដោះស្រាយ ហើយប្រកបដោយអារម្មណ៍ល្វីងជូរចត់ ពុំមែនងាយស្រួលនឹងកំចាត់ទេ ។

ដូចជាព្រះពុទ្ធអង្គ យើងចាំបាច់ត្រូវសាកល្បងក្នុងការអនុវត្តន៍ព្រះធម៌ ។ដោយព្រះពុទ្ធអង្គជាសព្វញ្ញូជន ព្រះធម៌រមែងផ្តល់នូវមូលដ្ឋានខាងបញ្ញាស្មារតីដ៏ប្រសើរសំរាប់ទាំងការស្វែងយល់ទាំងការដោះស្រាយអធិករណ៍។

សៀវភៅប្រភេទនេះចំនួនពាក់កណ្តាលទៀតនេះនឹងជួយបង្ហាញថា តើព្រះធម៌អាចជួយដោយជាក់ស្តែងយ៉ាងណា ក្នុងការកសាងសន្តិភាព?



www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធគឺជាអ្នកកសាងសន្តិភាព ជាមួយនឹងវិធីសមស្រប ទៅនឹងទំនាស់ ទាំងការអនុវត្តន៍ និងទាំងទ្រឹស្តី។

ភាគទី១នៃសៀវភៅនេះបានរៀបរាប់បង្ហាញនិកាសពីរ ក្នុងពេល ដែល ព្រះពុទ្ធអង្គបានធ្វើអន្តរាគមន៍ក្នុងទំនាស់។ យើងនឹងឃើញ ថា តើព្រះពុទ្ធអង្គសំរុះសំរួលយ៉ាងណា? លើការឈ្លោះគ្នារវាង គណៈសង្ឃពីរ ហើយបន្ទាប់មក តើព្រះអង្គបានធ្វើអន្តរាគមន៍ យ៉ាងដូចម្តេច? ក្នុងការបញ្ចៀសការបង្ហូរឈាមរវាងរដ្ឋពីរ ដែល ហៀបនឹងផ្ទុះសង្គ្រាមទៅហើយនោះ។

## មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់

មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ ត្រូវបានបង្កើតឡើងក្នុង ឆ្នាំ ១៩៩៦ ជាមជ្ឈមណ្ឌលឯករាជ្យ ស្ថិតនៅក្រោមការជួយឧបត្ថម្ភគាំទ្រពី វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។ មជ្ឈមណ្ឌលជួយគាំទ្រជ្រោមជ្រែង ដល់សហគមន៍នៃអ្នកអនុវត្តន៍ផ្ទាល់ ក្នុងការដោះស្រាយជំលោះ នូវវគ្គបណ្តុះបណ្តាលជំនាញ និងធនធាន ដើម្បីបង្កើន និងពង្រឹងសមត្ថភាពប្រជាជន និងស្ថាប័នកម្ពុជា ក្នុងការដោះ ស្រាយជំលោះ។ មជ្ឈមណ្ឌលកើតឡើងដោយមានការសហការពីសំណាក់ អង្គការរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលដែលចាប់អារម្មណ៍ក្នុងដំណើរការ អភិវឌ្ឍន៍ ការការពារ គ្រប់គ្រង និងដោះស្រាយទំនាស់។

បេសកកម្មរបស់មជ្ឈមណ្ឌលគឺ កសាងសមត្ថភាពរដ្ឋាភិបាល និងសង្គមស៊ីវិលឱ្យជាប់ទាក់ទងក្នុងដំណើរការសហការ លើការងារ ធ្វើការសំរេចចិត្ត។ ចំណុចផ្តោតសំខាន់នៃការប្រឹងប្រែងរបស់មជ្ឈមណ្ឌលគឺ ផ្តល់ពត៌មានដល់ដំណើរការសំរេចចិត្តសាធារណៈ តាមរយៈការស្រាវជ្រាវ វគ្គសិក្សា និងសកម្មភាពផ្សព្វផ្សាយជាមុខផ្សេងៗទៀតរបស់មជ្ឈមណ្ឌល។ មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ មានសង្ឃឹមថា នឹងបានចូលរួម ចំណែកក្នុងការប្រឹងប្រែងថែមទៀត ឆ្ពោះទៅរកការសំរេចឱ្យបាននូវសន្តិភាព យូរអង្វែងក្នុងប្រទេសកម្ពុជា។

១.៥០០៛